បន្ទាប់មកក្រុមយុវជនយុវនារី ខាងប្រុសខាងស្រី នាំគ្នារៀបចំម្ហូបអាហារសំរាប់អោយគូស្វាមីនិងភរិយាថ្មី និងភ្ញៀវទាំងអស់ដែលបានចូលរួម ។ ពួកគេទទួលទានយ៉ាងសប្បាយ ហើយបានឆ្អែតគ្រប់ៗគ្នា ។ ដល់ម៉ោងប្រាំពីរយប់ អ្នកទាំងពីរគោរពសំពះដល់ឪពុកម្ដាយបងប្អូនខាងប្រុស និងខាងស្រី ។ កូនកម្លោះគោរពសំពះដល់ឪពុកម្ដាយ និងបងប្អូនខាងស្រី ។ កូនក្រមុំគោរពសំពះដល់ឪពុកម្ដាយនិងបងប្អូនខាងប្រុស ។ មុនដំបូងប្អូនញ៉ៀគោរពសំពះដល់ឪពុកម្ដាយ បងប្រុស បងស្រី អ៊ំប្រុស អ៊ំស្រី ពូ និង មីងបង្កើតរបស់បងញ៉ល ដោយយកអង្កាំ និងបាយដំណើប មកបំពាក់បញ្ចុកអោយពួកគេគ្រប់ៗគ្នា ។ អង្កាំ និងបាយដំណើបជាការបង្ហាញពីទឹកចិត្តគោរព និងស្រឡាញ់របស់ប្អូនញ៉ៀចំពោះសាច់ថ្លៃ ។ បន្ទាប់មកបងញ៉លក៏គោរពសំពះដល់ឪពុកម្ដាយ បងប្រុស បងស្រី អ៊ំប្រុស អ៊ំស្រី ពូ និង មីង បង្កើតរបស់ប្អូនញ៉ៀ ដោយយកសាច់ក្រកនិងសាច់ជ្រូកបីជាន់ មកបញ្ចុកអោយពួកគេហូបគ្រប់ៗគ្នា ។ សាច់ក្រក និងសាច់ជ្រូកបីជាន់ជាការបង្ហាញពីទឹកចិត្ត គោរពនិងស្រឡាញ់របស់បងញ៉លចំពោះសាច់ថ្លៃរបស់គាត់ ៕
<u>សំនួរ</u>
-តើបងញ៉លបានរៀបការជាមួយនរណា?
-តើបងញ៉លមានមុខរបរអ្វី?</td></tr>
<tr><td>៥</td><td>រៀនសរសេរ</td><td>-ប្អូននើនដេញចាប់កូនពពែពូរបស់គាត់នៅលើស្មៅ ។
-បងស្រីរបស់បងតាយបានរើសអង្កាំរបស់គេជ្រុះតាមផ្លូវ ។</td></tr>
<tr><td>៦</td><td colspan="2">ចូរជ្រើសរើសព្យញ្ជនៈ " ញ " សរសេរប្រកបជាមួយស្រៈអោយបានបីពាក្យខាងក្រោមនេះ ៖
ជ្រើសរើសបីពាក្យខាងលើ សរសេរតែងប្រយោគអោយបានបីខាងក្រោមនេះ ៖</td></tr>
<tr><td>៧</td><td colspan="2">គ្រូអានអត្ថបទអោយសិស្សស្ដាប់</td></tr>
<tr><td></td><td colspan="2"><u>ស្ត្រីមានផ្ទៃពោះ</u>
ត្រូវការជាចាំបាច់នូវចំណីអាហារសំរាប់ជួយពង្រឹងបង្កើនឈាម ។ ស្ត្រីមានផ្ទៃពោះមិនអោយញ៉ាំស្រា នាំមានបញ្ហាដល់ទារក ។ ថ្នាំមានស្រាអាចញ៉ាំបន្តិចបន្តួចបាន ។ បន្លែស្លឹកពណ៌បៃតង ស៊ុត សាច់ ឬ ត្រី និងសណ្ដែក គាត់អាចញ៉ាំបាន ។

<u>ដើម្បីអោយមានទឹកដោះល្អ</u>
ដើម្បីអោយមានទឹកដោះល្អ អោយបានគ្រប់គ្រាន់សំរាប់បំបៅកូន ៖ ស្ត្រីដែលបំបៅដោះកូនមិនត្រូវញ៉ាំស្រា នាំមានបញ្ហាដល់កូន ។ ថ្នាំមានស្រាអាចញ៉ាំបន្តិចបន្តួចបាន ។ ត្រូវញ៉ាំចំណីអាហារទាំងបីក្រុមអោយបានបីដងក្នុងមួយថ្ងៃ ៖ ត្រូវញ៉ាំទឹក ឬ ភេសជ្ជៈពី ៨ ទៅ ១០ កែវជារៀងរាល់ថ្ងៃ ជាពិសេសញ៉ាំទឹកដោះគោបីកែវយ៉ាងតិចក្នុងមួយថ្ងៃ ។
ទារកមានអាយុ ១ ឆ្នាំ ត្រូវបន្តបំបៅដោះតទៅទៀត -ត្រូវលាងដៃទាំងពីររបស់កូន</td></tr>
</table>

	អោយបានស្អាតមុននិងញ៉ាំចំនីអាហារ ។ កុមារត្រូវញ៉ាំចំណីអាហារនៃក្រុមនីមួយៗនៃ "ចំណីអាហារទាំងបីក្រុម" បីពេលក្នុងមួយថ្ងៃ ហើយជាមួយនឹងក្រុមគ្រួសារទាំងអស់គ្នាដែរ ។ ផ្តល់ចំណីបំប៉នបន្ទាប់បន្សំនៅចន្លោះពេលបាយ ហើយអោយកូនតូចញ៉ាំអាហារសំរាប់កុមារជាដុំតូចៗ ។ **<u>ការអោយចំណីដល់កូនតូចៗ</u>** ទារកទើបនឹងកើតរហូតដល់ ៦ ខែ អោយបៅដោះម្តាយតែប៉ុណ្ណោះ! -កុំអោយទឹក -កុំអោយបបរ -កុំអោយទឹកដោះគោ -កុំអោយអាហារផ្សេងទៀត ។ ទារកមានអាយុ ១ ឆ្នាំត្រូវតែអោយបៅដោះម្តាយ អោយញ៉ាំបបរលាយជាមួយចំណីអាហារសំរាប់សាងសង់រាងកាយ ៤ ដងក្នុងមួយថ្ងៃ ។ ចំណីអាហារសំរាប់សាងសង់រាងកាយមានសណ្តែកបាយកិនរួចហើយ យកសំបកវាចេញ បុកស្ងឹកមានពណ៌បៃតងដែលធ្លាប់ហូបអោយម៉ត់ ស៊ុតស្ងោរឆ្អិននិងទឹកដោះគោ ។ បេះត្រីងៀតជាដុំតូចៗ ប្រើត្បាល់ដើម្បីបុកអាហារសាងសង់រាកាយ ដាក់បន្ថែមបបរទារក ។ ជាការសំខាន់ណាស់ដែលយើងអោយកូនតូចៗញ៉ាំផ្លែឈើ ដូចជាចេកទុំ ក្រូចនិងល្ហុងទុំជាដើម ។ កុមារអាយុ ២ ឆ្នាំ សូមបញ្ឈប់ការបំបៅដោះបន្តិចម្តងៗ បន្ថែស្ងឹកពណ៌បៃតង កូនតូចនេះត្រូវតែញ៉ាំចំណីអាហារតាមធម្មតាជាមួយនឹងក្រុមគ្រួសារគឺបីពេលក្នុងមួយថ្ងៃ ផ្តល់ចំណីបំប៉នបន្ទាប់បន្សំនៅចន្លោះពេលបាយ ។ **<u>សំនួរ</u>** ១-កូនក្មេងចាប់ពីអាយុកើតមករហូតទៅ៦ខែ តើយើងត្រូវផ្តល់អ្វីខ្លះសំរាប់អោយវាញ៉ាំ? ២-កូនក្មេងចាប់ពីអាយុ៦ខែទៅ១ឆ្នាំ តើយើងត្រូវបញ្ចុកម្ហូបអាហារអ្វីសំរាប់វា? ៣-មានម្ហូបអាហារប៉ុន្មានមុខ ដើម្បីរូបរាងកាយរបស់វាឆាប់ធំធាត់និងមានសុខភាពល្អ? ៤-ស្ត្រីមានផ្ទៃពោះ តើមានម្ហូបអាហារអ្វីសំរាប់អោយគាត់បរិភោគ ដើម្បីទារកក្នុងផ្ទៃពោះនិងគាត់មានសុខភាពល្អ?
១១	**មេរៀនទី៤២**
	បង្រៀនព្យញ្ជនៈពិសេស | ន - ញ - ម - ង
	ពាក្យគន្លឹះ | **មមិ នហាឆី**
១២	រៀនអាន
	<u>រៀនអានប្រយោគដែលមាជើង (្)</u>

	- នៅពេលយប់សត្វប្រចៀវ ហើរចេញពីរន្ធឈើទៅរកចំណីស៊ីនៅខាងក្រៅ ។ មេឃជិតភ្លឺសត្វប្រចៀវនោះហើរមកចូលរន្ធឈើនោះវិញ ។ - ថ្ងៃនេះខ្ញុំទៅរកត្រីជាមួយនឹងមិត្តភក្តិនៅក្នុងព្រៃ ។ ពេលបានត្រីហើយពួកខ្ញុំនឹងនាំគ្នាអាំងត្បុតត្រីទាំងនោះអោយវាក្រៀមល្អ ។ - ជីតារបស់ខ្ញុំចេះនិទានរឿងបុរាណនិងប្រវត្តពង្សាវតារអោយកូនចៅស្ដាប់ ។ - ឪពុកម្ដាយពូម៉ារធ្វើចំការជិតទឹកធ្លាក់មួយ ។ ក្នុងចំការនោះគាត់ដាំស្រូវនិងពោតលូតលាស់បានល្អណាស់ ។ - កាលពីម្សិលមិញបងរបស់ខ្ញុំនាំប្រពន្ធកូនរបស់គាត់ដើរកំសាន្ត នៅលើភ្នំណាម់លៀត ។ - មិត្តភក្តិខ្ញុំជាជាងផ្ទះ ។ គាត់មានពន្លាក ម៉ែត្រ ដែកគោល ដើម្បីធ្វើផ្ទះ ។ - បងថ្លៃប្ដីបងស្រីជីដូនមួយរបស់ខ្ញុំ យកកាំបិតធំចាក់កជ្រូកចេញឈាម ហើយយកត្រឡោកមួយត្រងឈាមនោះនៅខាងក្រោម ។ - បងយ៉ាងនិងប្អូនទីងជិះក្របីពីវាលស្មៅធ្វើដំណើរវិលត្រឡប់មកផ្ទះរបស់ពួកគេវិញ ។ - ប្អូនទីងចាក់ទឹកឆ្អិនកន្លះកែវអោយបងយ៉ាងពិសា ។ - នៅរដូវក្ដៅ ថ្ងៃក្ដៅខ្លាំងស្លឹកឈើងាប់ជ្រុះពីមែករបស់វា ដល់រដូវវស្សាស្លឹកឈើនឹងចាប់ផ្ដើមដុះលូតលាស់ឡើងវិញ ។ -អ៊ំក្រាក់ចេះធ្វើរទេះគោ ។ គាត់លក់រទេះគោនោះ ទិញបានកូនគោមួយក្បាល ។
១៨	ចូរជ្រើសរើសពាក្យនីមួយៗខាងលើ ហើយតែងអោយបានបួនប្រយោគខាងក្រោមនេះ ៖
១៩	រៀនអាន
	<u>នើនជាក្មេងឧស្សាហ៍ឃ្វាលគោក្របីនិងរកម្ហូប</u> ថ្ងៃមួយមានក្មេងម្នាក់ឈ្មោះនើន ទៅរកក្របីដែលបាត់ពីថ្ងៃមុន ។ ក្របីនោះបាត់យូរថ្ងៃហើយ ។ នើនទៅរកនៅវាលស្រែដែលមានបឹងមួយ ។ នើនឃើញក្របីរបស់ខ្លួននៅទីនោះហើយក៏ដឹកក្របីពីបឹងនោះមកវិញ ។ នើនឃើញត្រីជាច្រើនមកក្បែរជើងក្របី ។ នើនចង

<table>
<tr><td></td><td colspan="2">ក្របីនៅក្នុងស្រែ ហើយត្រឡប់មកផ្ទះប្រាប់ប្អូននិងពូ ដើម្បីទៅបាចទឹកបឹងនោះ ។ ពេលធ្វើដំណើរពីផ្ទះមក នើនឃើញពូរបស់គាត់កាន់ខ្សែ ហើយសួរ ៖ "លោកពូ! តើពូកាន់ខ្សែនេះមកធ្វើអ្វី?" ពូប្រាប់ ៖ "ខ្សែនេះសំរាប់ចងធុងបាចទឹកណាក្មួយ" ។ ប្អូននិងពូរបស់នើននាំគ្នាបាចទឹកបឹងក្នុងស្រែ ។ ឯនើនទៅស្រាយចំណងក្របី ហើយមកចងនៅក្បែរទឹកបឹងដែលគេកំពុងតែបាចនោះវិញ ដើម្បីងាយស្រួលមើលវា ។ បន្ទាប់មកនើនក៏ទៅជួយពូ និងប្អូនមកបាចទឹកបឹងនោះដែរ ។
ពេលបាចទឹករីងអស់ហើយ ពួកគេនាំគ្នាចុះទៅចាប់ត្រីក្នុងបាតបឹង ។ នើននិយាយ ៖ "ពូអើយ! យើងបានត្រីច្រើនណាស់" ។ ពេលពួកគេចាប់ត្រីទាំងនោះដាក់ក្នុងកាផាពេញ ហើយក៏យកត្រីទៅដាក់ក្នុងធុងបានកន្លះធុងទៀត ។ បន្ទាប់មកពូបង្គាប់អោយប្អូនរបស់នើនទៅបង្កាត់ភ្លើង ដើម្បីអាំងត្រីហូប ។ ពេលអាំងត្រីរួចហើយ ក៏នាំគ្នាហូប ។ ក្រោយមកពួកគេនាំគ្នាមកផ្ទះ ដោយស្ពាយកាផា និងយួរធុងដែលមានត្រីផង ។ ចំណែកនើនក៏ដេញក្របីដើរពីក្រោយពូនិងប្អូន ។ មកដល់ផ្ទះប្អូនរបស់នើនយកត្រីនោះទៅធ្វើសម្ល ។ ពេលចំអិនរួចរាល់ហើយ ក៏លើកសម្លដាក់លើគ្រែ ដោយមិនទុកដាក់អោយបានល្អ ។ រួចទៅងូតទឹកនៅឯអូរបាត់ ។
ពេលនើនជាបងត្រឡប់មកពីដេញក្របី អោយចូលក្រោលវិញ ហើយចូលក្នុងផ្ទះស្រាប់តែឃើញឆ្មាកំពុងស៊ីត្រីនៅក្នុងឆ្នាំង ។ ឃើញឆ្មាស៊ីត្រីក្នុងឆ្នាំ ដែលដាក់នៅលើគ្រែដូចនេះ នើនខឹងណាស់ ក៏យកឈើមកដេញវាយឆ្មា ហើយឆ្មានោះក៏រត់ទៅបាត់ ។ នើនស្តាយសម្លត្រីនោះណាស់ ។ នើនធ្វើសម្លម្តងទៀត ដោយយកត្រីអណ្តែងមកធ្វើសម្ល ហើយសម្លនោះច្រើនទៀតផង ។ ពេលត្រឡប់មកពីចំការវិញ ឪពុកម្តាយរបស់នើនហូបសម្លត្រី ដែលកូនធ្វើនោះយ៉ាងឆ្ងាញ់ ៕
<u>សំនួរ</u>
-នើនដើរទៅរកក្របី តើគាត់បានឃើញអ្វីខ្លះ?
-ហេតុអ្វីបានជានើនវាយឆ្មារបស់គាត់?</td></tr>
<tr><td>១៩</td><td colspan="2">មេរៀនទី៤៣</td></tr>
<tr><td></td><td>បង្រៀនព្យញ្ជនៈ</td><td>រ</td></tr>
<tr><td></td><td>ពាក្យគន្លឹះ</td><td>ពីងពាង សត្វរៃ</td></tr>
<tr><td>២០</td><td colspan="2">រៀនអាន</td></tr>
<tr><td></td><td colspan="2"><u>ពីងពាងនិងសត្វរៃស្វែងរកទីជំរក</u>
កាលពីព្រេងនាយ មេពីងពាងបានប្រមូលផ្តុំគ្នា ដើម្បីពិភាក្សាគ្នាអំពីទីជំរករស់នៅ ។ វាបានទៅប្រាប់ក្រុមពីងពាងនៅក្នុងភូមិ ក្រុមពីងពាងនៅក្នុងព្រៃ និង ក្រុមសត្វរៃផងដែរ ។ ពីងពាងនៅក្នុងព្រៃមានពីរក្រុម ក្រុមពពួកអាពីង និង ពពួកសត្វពីងពាងពណ៌ក្រឡា</td></tr>
</table>

លឿងខ្មៅ ។

ដល់ពេលកំណត់ដែលត្រូវប្រមូលផ្ដុំគ្នាក្នុងព្រៃនោះ សត្វរៃបានចូលរួមពិភាក្សាគ្នានៅទីនោះដែរ ។ បន្ទាប់មកមេពីងពាងក៏សួរទៅក្រុមរបស់វានោះ ៖ "ពពួកសត្វពីងពាងដែលនៅក្នុងភូមិ និង ពពួកសត្វពីងពាងដែលនៅក្នុងព្រៃ តើពួកឯងទាំងអស់គ្នាចង់រស់នៅកន្លែងណាខ្លះ?" ពពួកពីងពាងនៅក្នុងភូមិឆ្លើយ ៖ "ខ្ញុំចង់តែរស់នៅក្នុងភូមិប៉ុណ្ណោះ ខ្ញុំមិនចង់រស់ក្នុងព្រៃនោះទេ ។ នៅក្នុងភូមិងាយស្រួលបំផុត ចង់រស់នៅក្នុងផ្ទះក៏បាន នៅក្នុងជង្រុកស្រូវក៏បាន ឬក៏កន្លែងណាផ្សេងទៀត ស្រេចតែចិត្តខ្ញុំ ។ បើសិនជារស់នៅក្នុងព្រៃវិញ អត់មានកន្លែងសំរាប់ជ្រកនៅ ពេលមានភ្លៀងពិតជារងាណាស់" ។

បន្ទាប់មកមេពីងពាងក៏សួរទៅក្រុមពីងពាង ដែលរស់នៅក្នុងព្រៃនោះទៀត ៖ "បើសិនជាដូច្នេះ ចុះពួកឯងទាំងអស់គ្នានេះយ៉ាងម៉េចដែរ? ឥឡូវនេះពួកឯងចង់រស់នៅកន្លែងណា? ក្នុងភូមិ? ឬ នៅក្នុងព្រៃ?" ក្រុមពពួកពីងពាងពណ៌ក្រឡាលឿងខ្មៅឆ្លើយ ៖ "ពួកខ្ញុំចង់រស់នៅក្នុងព្រៃស្រោងដ៏ធំល្វឹងល្វើយ ។ នៅកន្លែងនោះទើបមានដើមឈើសំរាប់ខ្ញុំធ្វើផ្ទះសំបែង និង ធ្វើចំការ ។ បើសិនជារស់នៅក្នុងភូមិវិញ សូម្បីតែដើមឈើដើមឫស្សីពួកគេកាប់ចោលអស់រលីង តើអោយខ្ញុំរស់នៅម្ដេចកើតទៅ? ខ្ញុំមិនចង់រស់នៅទេ" ។ ពពួកអាពីងនិយាយទៀត ៖ "ពួកខ្ញុំចង់រស់នៅក្នុងព្រៃ ដូចពួកគេទាំងអស់គ្នានេះដែរ ។ តែពួកខ្ញុំចង់ធ្វើផ្ទះក្នុងដីដូចពពួកក្ដាម ទើបមានសេចក្ដីសុខជាង ។ បើនៅក្នុងភូមិព្ធ តែសម្រែក គេស្រែកឡូឡា វាយប្រពន្ធកូន ស្រែកយំរាល់ថ្ងៃ គ្មានសេចក្ដីសុខសាន្តទេ ។

ក្រោយមកមេពីងពាងនោះក៏សួរទៅសត្វរៃទៀត ៖ "បើដូច្នេះ ពពួករៃឯងយល់យ៉ាងម៉េចដែរ? ពួកឯងចង់រស់នៅក្នុងភូមិ? ឬ រស់នៅក្នុងព្រៃស្រោងធំៗ?" ក្រុមរៃឆ្លើយ ៖ "ពួកខ្ញុំមិនដឹងដែរលោកស្រី បើសិនជារស់នៅក្នុងភូមិ ច្បាស់ជាគេជេរប្រមាថជាមិនខាន? ពួកខ្ញុំធ្លាប់តែស្រែកច្រៀងបន់ស្រន់ហៅទឹកភ្លៀង ដើម្បីស្រោចស្រប់មកលើផែនដី និងព្រៃព្រឹក្សាទាំងអស់ ។ ឥឡូវនេះពួកខ្ញុំសូមរស់នៅក្នុងព្រៃស្រោង ដែលឆ្ងាយពីភូមិមនុស្សរស់នៅ តើបានដែរទេ?" "ចា៎! បាន" ។

ក្រោយពេលពិភាក្សាគ្នាហើយ ពួកគេបំបែកគ្នាត្រឡប់ទៅវិញរៀងៗខ្លួន ។ ក្រុមពីងពាងរស់នៅក្នុងភូមិវិលត្រឡប់ទៅក្នុងភូមិវិញ ។ ក្រុមពីងពាងរស់នៅក្នុងព្រៃវិលត្រឡប់ទៅក្នុងព្រៃ ។ ពីងពាងរស់នៅក្នុងភូមិធ្វើសំបុកនៅក្នុងផ្ទះរបស់មនុស្សរស់នៅ ឬក៏នៅក្នុងជង្រុកស្រូវ ។ ពួកវាធ្លាប់តែរកស៊ីចំនីនៅពេលយប់ប៉ុណ្ណោះ នៅពេលថ្ងៃវាដេក ។

ក្រុមពីងពាងពណ៌ក្រឡាលឿងខ្មៅនាំគ្នាធ្វើសំបុកនៅ នឹងរន្ធដើមឈើ ។ ពួកវាតែងតែវាយសំណាញ់តាមផ្លូវដែលមនុស្សយើងធ្វើដំណើរក្នុងព្រៃ ដើម្បីចាប់សត្វល្អិតៗមកស៊ី ។ ពួកវាតែងតែរកស៊ីនៅពេលយប់ និងពេលថ្ងៃ ។ ពួកអាពីងទៅដល់ក្នុងព្រៃ នាំគ្នាត្បាលដីធ្វើរន្ធទីជំរកនៅ ដូចពួកសត្វក្ដាម ។ ពួកវាតែងតែរកចំនីនៅពេលយប់ប៉ុណ្ណោះ ពេលថ្ងៃវានៅក្នុងរន្ធ ។ ចំណែកសត្វរៃវិញ វានាំគ្នាហើរទៅរកព្រៃស្រោងដែលមាដើមឈើច្រើន ។ ដល់រដូវ

	ប្រាំងវាស្រែកយំឆ្លើយឆ្លងគ្នាជារៀងរាល់ថ្ងៃ ដើម្បីអោយទឹកភ្លៀងបង្អុរមក ។ ដល់រដូវវស្សាវាសកសំបកខ្លួនទាំងអស់ទុកចោលនៅជាប់ នឹងដើមឈើ រួចនាំគ្នាវិលត្រឡប់ទៅក្នុងដីវិញ ជាកន្លែងរស់នៅអចិន្ត្រៃយ៍ ៕ **<u>សំនួរ</u>** -ក្រុមពីងពាងទាំងអស់ធ្លាប់នៅទីណាខ្លះ? -ហេតុអ្វីបានជាមេពីងពាងប្រមូលផ្ដុំគ្នា? -តើកន្លែងរស់នៅពិតប្រាកដសត្វរៃនៅទីណា?	
២៤	រៀនសរសេរ	-ថ្ងៃនេះតាវាយនិងនើននាំគ្នាទៅរកត្រី ។ -កូនបងស្រីរបស់នើនចេះវារ ។
២៥	ចូរជ្រើសរើសព្យញ្ជនៈ " វ " សរសេរប្រកបអោយបានប្រាំពាក្យ ។ ជ្រើសរើសបីពាក្យនោះ ហើយតែងអោយបានបីប្រយោគខាងក្រោមនេះ ៖	
២៦	គ្រូអានអត្ថបទអោយសិស្សស្ដាប់	
	<u>ម្ហូបអាហាររបស់យើង</u> មនុស្សទាំងអស់ចាស់ក្មេងប្រុស ឬ ស្រីត្រូវញ៉ាំម្ហូបអាហារបីក្រុមនេះជារៀងរាល់ថ្ងៃ ។ អាហារថាមពល ធ្វើអោយយើងមានកំលាំង ។ អាហារសាងសង់ ធ្វើអោយយើងមានរូបកាយមាំមួន ។ អាហារការពារ អាចជួយការពារជំងឺបាន ។ កូននេះស្គម ឥតមានកំលាំងព្រោះវាមានជំងឺ និងគ្មានជាតិវីតាមីន ។ ម្ដាយរបស់កូននេះក៏ហេវហត់ គ្មានកំលាំងធ្វើការ ហើយស្លេកស្លាំងដែរ ។ ម្ដាយក្មេងនេះបានទៅទិញថ្នាំពីផ្សារមកលេបជាច្រើនដងហើយ តែមិនត្រូវ ។ ពេលពេទ្យឃុំចុះមកចាក់ថ្នាំការពារជំងឺ គាត់និយាយប្រាប់ពេទ្យនោះថាគាត់ឥតមានកំលាំងទេ ។ ពេលនេះពេទ្យបានពិនិត្យមើលក្នុងភ្នែករបស់គាត់ ឃើញខ្វះជាតិដែក ។ ពេទ្យបានណែនាំប្រាប់ម្ដាយក្មេងនោះថាអោយហូបសាច់ពងមាន់ និងបន្លែដែលមានពណ៌បៃតងចាស់ ។ ឃើញកូនគាត់ស្គមខ្លាំង ពេទ្យបានប្រាប់ទៅម្ដាយអោយផ្ដល់អាហារអោយកូនហូបអោយបានគ្រប់គ្រាន់ដែលមានសាច់ផ្សេងៗ ដូចជា ៖ ពងទា ខ្លាញ់ បន្លែ ផ្លែឈើ ។ ម្ដាយរបស់ក្មេងនោះបានឆ្លើយប្រាប់ពេទ្យថាកូនរបស់គាត់ចង់ហូបតែបាយទទេ ។ វាមិនចង់ហូបម្ហូបអាហារផ្សេងៗទេ ។ នៅចំការរបស់គាត់គ្មានដាំបន្លែច្រើនមុខទេ ។ គ្រូពេទ្យបានប្រាប់ទៅម្ដាយក្មេងនោះថាមិនចាំបាច់ហូបបន្លែគ្រប់មុខទេ បើនៅក្នុងចំការនោះមានបន្លែអ្វីត្រូវអោយវាហូបបន្លែនោះក្នុងមួយថ្ងៃពីរឬបីដង ។ ចាប់ពីពេលនោះមកម្ដាយរបស់ក្មេងនោះបានព្យាយាមអោយកូនរបស់គាត់ហូបអាហារតាមគ្រូពេទ្យណែនាំ ។ តាំងពីពេលនោះមកកូនរបស់គាត់ចាប់ផ្ដើមមានសាច់ មានឈាម និង កំលាំងមាំមួន ។ ចំណែកម្ដាយក៏ហូបអាហារតាមគ្រូពេទ្យណែនាំដែរ ។ ឥឡូវនេះគាត់មានកំលាំងធ្វើការបានវិញហើយ ៕ **<u>សំនួរ</u>**	

<table>
<tr><td></td><td colspan="2">-តើមានម្ហូបអាហារប៉ុន្មានក្រុមសំរាប់អោយយើងបរិភោគប្រចាំថ្ងៃ?
-តើមានម្ហូបអាហារអ្វីខ្លះ ធ្វើអោយយើងមានកំលាំងមាំមួន?
-បើយើងទទួលម្ហូបអាហារមិនគ្រប់គ្រាន់ តើរូបកាយយើងទៅជាយ៉ាងណា?</td></tr>
<tr><td>២៩</td><td colspan="2">មេរៀនទី៤៤</td></tr>
<tr><td></td><td>បង្រៀនស្រះ</td><td>ឺ</td></tr>
<tr><td></td><td>ពាក្យគន្លឹះ</td><td>ក្រពើ</td></tr>
<tr><td>៣០</td><td colspan="2">រៀនអាន</td></tr>
<tr><td></td><td colspan="2"><u>រឿងនិទានយាយចាស់តាចាស់និងក្រពើ</u>
មានថ្ងៃមួយតាចាស់និងយាយចាស់អត់មានអុសសំរាប់ដុត ។ តាចាស់និយាយទៅកាន់យាយចាស់ ៖ "យាយអើយ ! តើត្រូវធ្វើយ៉ាងម៉េចបើអត់មានអុសដុតសោះ បានអីដាំបាយសម្ល? ទៅរកអុសសិន!" យាយចាស់ឆ្លើយ ៖ "យើងទៅបាន តែយករទេះគោយើងនេះទៅ!" តាចាស់និងយាយចាស់ក៏ជិះរទេះគោពីរនាក់ប្តីប្រពន្ធ ។ នៅលើរទេះគោនោះមានដឹងមួយ ទឹកនិងរបស់របរហើយក៏ចេញដំណើរ ។ ឯរទេះគោឮង៉េតង៉ក់ៗ ។ ទៅដល់ព្រៃគាត់ដាក់សំភារៈចុះពីលើរទេះគោ ។
តាចាស់និងយាយចាស់នោះឃើញក្រពើ ។ ក្រពើនោះស្រេកទឹកហើយរកទឹក ដើម្បីផឹកគ្មានសោះ ។ ទឹកនៅកន្លែងនោះរីងស្ងួតអស់នៅពេលរដូវប្រាំង ។ ក្រពើនោះស្រេកទឹកខ្លាំងណាស់ ថ្ងៃក៏ក្តៅខ្លាំងវារមិនរួចសោះ ស្ងួតកហាមាត់នៅនឹងមួយកន្លែងហើយក៏អង្វរតាចាស់និងយាយចាស់អោយជួយ ។
តាចាស់ និងយាយចាស់ឃើញក្រពើនោះអាណិតណាស់ ក៏លើកក្រពើនោះចងលើទូករទេះគោខ្លួនឯង តាចាស់និយាយ ៖ "តើក្រពើឯងកើតអីហ្នឹង?" ក្រពើឆ្លើយ ៖ "ហ៊ឺ! តាអើយ! ខ្ញុំវារលែងរួចហើយណាលោកតាអើយ! រកទឹកផឹកក៏គ្មានដែរ សុំអោយលោកតាជួយខ្ញុំដោយជូនខ្ញុំទៅដល់ទឹកអូរផង" ។ តាចាស់ឆ្លើយ ៖ "មិនអីទេចៅក្រពើ! តាជូនចៅក្រពើឯងហើយ" ។ ក្រោយមកតាចាស់ និងយាយចាស់នោះបររទេះទៅដល់ទឹកត្រពាំង ។ តាចាស់សួរក្រពើ ៖ "ចៅក្រពើអើយ! តាត្រូវដាក់ចៅឯងក្នុងត្រពាំងនេះឬទេ?" ក្រពើឆ្លើយ ៖ "បាទ! ទឹកត្រពាំងនេះហើយលោកតា!" ។ តាចាស់ក៏ស្រាយចៅក្រពើពីលើទូករទេះ ហើយក៏ដាក់ក្នុងទឹកត្រពាំង ។ ឯក្រពើនោះផឹកទឹកឆ្អែត ហើយនិយាយទៅកាន់តាចាស់ ៖ "ហ៊ឺស! លោកតាឯងចងខ្ញុំឈឺខ្លាំងណាស់អំបាញ់មិញនេះ ។ ឥឡូវនេះខ្ញុំខាំស៊ីយាយតាឯងហើយ" ។ តាចាស់ឆ្លើយ ៖ "ហ៊ឺ! ចៅក្រពើអើយ! កុំអាលប្រញាប់ស៊ីអី សូមចៅក្រពើឯងចាំតាមួយថ្ងៃពីរថ្ងៃសិន ។ បើចៅឯងប្រញាប់ស៊ីពួកខ្ញុំដូច្នេះចៅក្រពើឯងមិនទាន់មានកំលាំងទេ ពីព្រោះថាចៅក្រពើឯងទើបតែអត់ទឹកអស់រយៈពេលយូរថ្ងៃហើយ ។ ដូច្នេះចៅក្រពើឯងចាំតានិងយាយនៅកន្លែងនេះសិន បន្តិចទៀតតានិងយាយត្រឡប់មកវិញអោយចៅក្រពើឯងស៊ីចុះ" ។ ក្រពើ</td></tr>
</table>

	ឆ្លើយ ៖ "អើ! បើអញ្ជឹងតានិងយាយត្រឡប់មកមែនណា៎ ។ បើមិនត្រឡប់មកវិញទេនោះខ្ញុំនឹងទៅខាំស៊ីតានិងយាយនៅនឹងផ្ទះតែម្ដង" ។ តាចាស់និងយាយចាស់ឆ្លើយ ៖ "ចៅឯងកុំភ័យ" ។ តាចាស់និងយាយចាស់គិតព្រួយបារម្ភណ៍ណាស់ ក៏នឹកឃើញថាទន្សាយចេះកាត់ក្ដីក៏បបួលទន្សាយទៅកាត់ក្ដី ។ ទន្សាយសួរក្រពើ ៖ "តើតាចាស់និងយាយចាស់បានធ្វើក្រពើឯងអ្វីខ្លះ?" ក្រពើឆ្លើយ ៖ "តាចាស់នេះចងខ្ញុំឈឺណាស់" ។ ទន្សាយនិយាយ ៖ "បើអីចឹងសូមតាឯងចងក្រពើអោយខ្ញុំមើលម្ដងទៀត" ។ តាចាស់នោះក៏ចងក្រពើនៅលើទូករទេះដូចដើមវិញម្ដងទៀត ។ តាចាស់សួរក្រពើ ៖ "តាចងចៅក្រពើឯងប៉ុណ្ណឹងមែនទេ?" ក្រពើឆ្លើយ ៖ "មិនទាន់ល្មមទេ" ។ តាចាស់រឹតបន្តិចទៀត រឹតរួចហើយសួរក្រពើទៀត ៖ "តើល្មមឬទេ?" ក្រពើឆ្លើយ ៖ "មិនមែនតែប៉ុណ្ណឹងទេ" ។ តាចាស់រឹតថែមទៀត ហើយសួរក្រពើ ៖ "តើប៉ុណ្ណឹងបានហើយឬនៅ ចៅក្រពើ?" ក្រពើឆ្លើយ ៖ "បាទ! បានហើយ" ។ ទន្សាយនិយាយ ៖ "តើតាឯងទុកដឹងធ្វើអ្វី? ម្ដេចក៏មិនកាប់ក្បាលវាទៅ" ។ តាចាស់ក៏យកដឹងកាប់ក្បាលក្រពើនោះរហូតដល់ងាប់ ៕ **<u>សំនួរ</u>** ១ -ហេតុអ្វីបានជាក្រពើចង់ស៊ីយាយហើយនឹងតា? ២ -នរណាខ្លះបានជួយដល់យាយតាអោយបានរួចជីវិត?	
៣៣	រៀនសរសេរ	-នើនបានឃើញក្រពើមួយនៅក្បែមាត់ច្រាំង ។ -នើនកំពុងទាត់ផ្លែម្នាស់លេងនឹងជើងរបស់គាត់ ។
៣៤	ចូរជ្រើសរើសស្រៈ " ី " សរសេរប្រកបអោយបានប្រាំពាក្យខាងក្រោមនេះ ៖	
៣៤	ចូរជ្រើសរើសប្រាំពាក្យខាងលើ សរសេរតែងប្រយោគអោយបានប្រាំខាងក្រោមនេះ ៖	
៣៥	**មេរៀនទី៤៥**	**មេរៀនរំលឹកឡើងវិញ**
៣៥	រៀនអាន	
	<u>រឿងទន្សាយនិងក្របី</u> កាលពីយូរមកហើយ មានដីរនឹងក្របីរស់នៅក្នុងភូមិជាមួយមនុស្ស ។ មានថ្ងៃមួយក្របីនោះបានជួបនឹងសុភាទន្សាយនៅឯវាលស្មៅដ៏ល្អរបស់វា ។ ក្របីមិនដឹងថាទន្សាយទើបតែមកពីណាទេ ។ ក្របីសួរទន្សាយ ៖ "លោកទន្សាយ តើលោកអញ្ជើញទៅណាមកណាដែរ?" ទន្សាយឆ្លើយ ៖ "ខ្ញុំមិនទៅណាមកណាទេ ខ្ញុំមកនេះចង់បបួលក្របីឯងទៅរកស្មៅ ដើម្បីស៊ីជាមួយគ្នាប៉ុណ្ណោះ ។ កាលពីថ្ងៃមុនខ្ញុំឡើងភ្នំខាងលើនោះបានឃើញកន្លែងភូមិចាស់គេ ហើយបានឃើញចំណីស៊ីច្រើនណាស់ណា៎! តើឯងចង់ទៅជាមួយនឹងខ្ញុំដែរឬទេ?" ក្របីឆ្លើយ ៖ "បាទ! បើអីចឹង ខ្ញុំទៅជាមួយនឹងឯងហើយ" ។ ដឹងថាក្របីទៅជាមួយវា ទន្សាយនិយាយម្ដងទៀត ៖ "អើ! បើឯងយល់ព្រមទៅយ៉ាងនេះហើយ ខ្ញុំគិតថាយើងនាំគ្នាទៅឥឡូវនេះតែម្ដង ។ បើយើងពន្យាពេលយូរប្រហែលមានមនុស្សមកតាម យកឯងត្រឡប់ទៅភូនើនិញ	

យើងលែងបានទៅហើយ" ។

បន្ទាប់មកសុភាទន្សាយនឹងក្របីនាំគ្នាឡើងភ្នំ ។ សុភាទន្សាយដើរខាងមុខក្របី ព្រោះសុភាទន្សាយជាអ្នកនាំផ្លូវ ។ ពួកវាដើររហូតដល់កន្លែងមានទឹកត្រពាំង ។ ទន្សាយនាំក្របីដើរវាងកាត់ឆ្ងាយពីទឹកត្រពាំងនោះបន្តិច ប៉ុន្តែក្របីស្រេកទឹកអស់កម្លាំងវាមិនអាចទ្រាំបាននឹងពន្លឺថ្ងៃឡើយ ។ វាបានឃើញទឹកត្រពាំងនោះហើយនិយាយ ៖ "អេ! លោកទន្សាយសូមឯងចាំខ្ញុំនៅទីនេះសិន ខ្ញុំទៅផឹកទឹកត្រពាំងមួយភ្លែត" ។ ទន្សាយឆ្លើយ ៖ "អើ!" ។

បន្ទាប់មកក្របីដើរសំដៅទៅទឹកត្រពាំងនោះ ដើម្បីផឹកហើយនឹងត្រាំខ្លួនរបស់វា ។ ដល់ជិតមាត់ត្រពាំងនោះ ស្រាប់តែវាបានឃើញស្មៅដុះខៀវខ្ចីដ៏ល្អ ។ វាដើរមកក៏ឆ្ងាយ ហើយស្រេកឃ្លានទៀត វាមិនអាចទ្រាំបានទេជាមួយនឹងស្មៅទាំងនោះ ។ វាគិតថាត្រូវតែស៊ីចំណីទាំងនោះសិន ភ្លេចគិតថាទន្សាយកំពុងតែចាំវា ដើម្បីឡើងទៅភ្នំខ្ពស់ ។ សុភាទន្សាយចាំយូរពេកក៏ចុះទៅខាងជើងភ្នំនោះបានជួបជាមួយនឹងក្រពើ ហើយនិយាយទៅក្រពើនោះ ៖ "អេ! លោកក្មួយក្រពើ! ខ្ញុំសូមពឹងឯងជួយប្រាប់ក្របី ដែលកំពុងតែត្រាំទឹកត្រពាំងខាងលើនោះអោយខ្ញុំផង ។ ខ្ញុំបានចាំវាយូរណាស់ទៅហើយ វាមិនឃើញមកសោះ ណាមួយខ្ញុំឥឡូវនេះងងុយដេកទៀត ប្រហែលខ្ញុំសូមដេកចាំក្នុងគម្ពោតព្រៃនេះសិនហើយ" ។ បន្ទាប់មកក្រពើទៅដល់ទឹកត្រពាំង ។ វាឃើញក្របីកំពុងតែត្រាំក្នុងទឹក ។ ក្រពើនោះកំពុងតែឃ្លានចំណីផងដែរ ។ រកអ្វីមកស៊ីគ្មានសោះ ។ វាគិតថាចុះទៅសំលាប់ក្របីដែលកំពុងតែត្រាំទឹកនោះតែម្តង ។ វាស្ទុះខាំបានជើងរបស់ក្របី ។ ក្របីស្រែកបោលឡើងអោយសុភាទន្សាយជួយ ៖ "លោកពូទន្សាយអើយ! សូមមកជួយខ្ញុំផង ក្រពើកំពុងតែខាំជើងខ្ញុំហើយ" ។ សុភាទន្សាយឮសម្រែករបស់ក្របីក៏ភ្ញាក់ឡើង ហើយរត់ស្ទុះទៅត្រពាំងនោះភ្លាម ឃើញក្រពើកំពុងតែខាំជើងក្របី ។

មួយរំពេចក្រោយមកដំរីមកដល់ទីនោះដែរ ។ ដំរីឃើញហេតុការណ៍កើតឡើងយ៉ាងសាហាវបែបនោះ ក៏ជួយទាញស្នែងក្របីឡើង ។ ក្របីរបូតពីមាត់ក្រពើនៅក្នុងទឹកត្រពាំងនោះមកឯដីគោកវិញ ។ ដំរីវាវាយក្បាលក្រពើ ឯក្រពើរត់ពួននៅក្នុងទឹកត្រពាំងនោះបាត់ទៅ ។

បន្ទាប់មកសុភាទន្សាយដំរីហើយនឹងក្របីនៅជាមួយគ្នា ។ ជួនពេលនោះសុភាទន្សាយបបួលដំរីនឹងក្របីឡើងទៅលើភ្នំនោះទៀត ។ ក្របីឮដូច្នោះក៏ប្រាប់គោលការណ៍ ដែលចង់ឡើងទៅភ្នំ អោយដំរីដឹង ៖ "បើសិនជាយើងឡើងភ្នំនោះដល់កំពូល យើងច្បាស់ជាក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិជាមិនខានឡើយ ពីព្រោះនៅទីនោះ សំបូររបស់របរណាស់ណាំ!" ដំរីសួរ ៖ "ពិតមែនឬ?" បន្ទាប់មកសុភាទន្សាយដំរីនឹងក្របីនាំគ្នាឡើងទៅលើភ្នំនោះ ។ ដល់ខាងលើភ្នំ ពួកវាបានឃើញដើមចេក ដើមអំពៅ អត់មានរបស់សំខាន់ដែលពួកវាត្រូវការនោះឡើយ ។ ឯដំរីវិញវាបានឃើញដើមចេក ដើមអំពៅជាចំណីរបស់វា ។ ដូច្នេះវាដកដើមចេកនិងដើមអំពៅស៊ី ។ ឯទន្សាយហើយនឹងក្របីវិញអត់មានរបស់អ្វីស៊ីទេ ។ ដូចនេះពួកវាបបួលដំរីត្រឡប់ទៅវិញ ។ ដំរីមិនព្រមត្រឡប់ទៅវិញសោះ ពីព្រោះវាអាល័យតែស៊ីដើមចេកនិងដើម

	អំពៅនៅលើភ្នំនោះ ។ ក្រោយពេលដែលបបួលដំរីមិនព្រមត្រឡប់ទៅវិញ សុភាទន្សាយនិងក្របីនាំគ្នាចុះចាំដំរីនៅខាងក្រោមជើងភ្នំ ។ ប៉ុន្តែដំរីលែងចង់ត្រឡប់ទៅផ្ទះវិញហើយ ពីព្រោះវាបានឃើញចំណីដ៏ឆ្ងាញ់របស់វានៅលើភ្នំ ។ ដូច្នេះដំរីនោះក៏ក្លាយជាដំរីព្រៃរហូតមកដល់សព្វថ្ងៃនេះ ។ បន្ទាប់មកសុភាទន្សាយនិងក្របីនាំគ្នាត្រឡប់ទៅភូមិដ្ឋានរបស់មនុស្សវិញ ។ ដល់ពាក់កណ្តាលផ្លូវសុភាទន្សាយសញ្ជឹងគិត បើសិនជាត្រឡប់ទៅផ្ទះច្បាស់ជាត្រូវមនុស្សស្តីបន្ទោស ដោយសារតែបាត់ដំរី ហើយណាមួយខ្លួនជាអ្នកតូចល្អិតផង បើត្រឡប់ដល់ផ្ទះច្បាស់ជាគេវាយមិនខាន ។ វាក៏រត់បែកចេញពីក្របី ហើយរកកន្លែងលាក់ខ្លួនក្នុងគុម្ពោតព្រៃរហូតមកទល់សព្វថ្ងៃនេះ ។ ឯក្របីវិលត្រឡប់ទៅវិញដោយម្នាក់ឯង ។ ទៅដល់ភូមិមនុស្សសួរវា ៖ "អាក្របី តើដំរីវានៅឯណាទៅ?" ក្របីឆ្លើយឡើង ៖ "វាប្រហែលវង្វេងក្នុងព្រៃ ឬមួយត្រូវខ្លាហែកស៊ីអស់ហើយមិនដឹង ។ ខ្ញុំរង់ចាំវានៅឯកន្លែងណាត់ជួបគ្នាយ៉ាងយូរ តែមិនឃើញវាមកសោះ ហេតុដូច្នេះទើបខ្ញុំវិលត្រឡប់តែម្នាក់ឯង" ។ បន្ទាប់មកមនុស្សនិយាយទៅក្របី ៖ "បើអីចឹងចាប់ខ្លួនឯងនេះធ្វើជាអាហាររបស់ពួកយើង" ។ វាឮមនុស្សថាយ៉ាងដូច្នោះ ក៏ភ័យខ្លាចជាខ្លាំងហើយក៏រត់ចូលក្នុងព្រៃក្លាយទៅជាក្របីព្រៃ រហូតមកដល់សព្វថ្ងៃនេះ ៕ **<u>សំនួរ</u>** -ក្រៅពីក្របី តើមានសត្វណាទៀតបានទៅជាមួយនឹងសុភាទន្សាយ? -តើសត្វដំរីបានវិលត្រឡប់ពីភ្នំមកភូនេីនិញដែរឬទេ? -តើមានសត្វប៉ុន្មានក្បាលបានវិលត្រឡប់មកភូមិវិញ?
៣៩	ចូរសរសេររឿងផ្សេងៗដែលអ្នកមាន ដូចជាជីវប្រវត្តិ រឿងនិទាន ឬអំពីធ្វើផ្ទះ តែងជាអត្ថបទមួយនៅខាងក្រោមនេះ ៖
៤០	**លំហាត់បំពេញប្រយោគ**
៤០	ខ្លះ ព្រៃភូមិចាស់ ពាក់កណ្តាល បាត់ ចាប់ ត្រឡប់ ភ្នំ មិន យូរ ខ្លាច ចូរជ្រើសរើសពាក្យខាងលើ មកបំពេញក្នុងប្រយោគនីមួយៗខាងក្រោមនេះ ៖
	បន្ទាប់មកសុភាទន្សាយដំរីហើយនឹងក្របីនៅជាមួយគ្នា ។ ជូនពេលនោះសុភាទន្សាយបបួលដំរីនឹងក្របីឡើងទៅលើភ្នំនោះទៀត ។ ក្របីឮដូច្នោះក៏ប្រាប់គោលការណ៍ដែលចង់ឡើងទៅភ្នំអោយដំរីដឹង ៖ "បើសិនជាយើងឡើងដល់កំពូលភ្នំនោះ យើងច្បាស់ជាក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិជាមិនខានឡើយ ពីព្រោះនៅទីនោះ មានរបស់ខ្លះដែលពួកយើងត្រូវការ" ។ ដំរីសួរ ៖ "ពិតមែនឬ?" បន្ទាប់មកសុភាទន្សាយដំរីនឹងក្របីនាំគ្នាឡើងទៅលើភ្នំនោះ ។ ដល់ខាងលើភ្នំ ពួកវាបានឃើញដើមចេក ដើមអំពៅ អត់មានរបស់សំខាន់ដែលពួកវាត្រូវការនោះឡើយ ។ ឯដំរីវិញបានឃើញដើមចេក ដើមអំពៅដែលជាចំណីរបស់វា ។ វាដកដើមចេកដើមអំពៅនៅក្នុងព្រៃភូមិចាស់របស់គេពីមុននោះស៊ី ។ ឯទន្សាយហើយនឹងក្របីវិញអត់មានរបស់អ្វីស៊ីទេ ។ ដូចនេះពួកវាបបួលដំរីត្រឡប់ទៅវិញ ។ ដំរីមិនព្រមត្រឡប់ទៅវិញសោះ,ពី

<table>
<tr><td></td><td colspan="2">ព្រោះវាអាល័យតែស៊ីដើមចេកដើមអំពៅនៅលើភ្នំនោះ ។ ក្រោយពេលដែលបបួលដំរីមិនព្រមត្រឡប់ទៅវិញ សុភាទន្សាយនឹងក្របីនាំគ្នាចុះតែពីរក្បាល ចាំដំរីនៅខាងក្រោមជើងភ្នំនោះ ប៉ុន្តែដំរីលែងចង់ត្រឡប់ទៅផ្ទះវិញហើយ ពីព្រោះវាបានឃើញចំណីដ៏ឆ្ងាញ់របស់វានៅទីនោះ ។ ដូច្នេះដំរីក្លាយទៅជាដំរីព្រៃរហូតមកទល់សព្វថ្ងៃនេះ ។
បន្ទាប់មកសុភាទន្សាយ និងក្របីនាំគ្នាត្រឡប់ទៅភូមិដ្ឋានរបស់មនុស្សវិញ ។ ដល់ពាក់កណ្ដាលផ្លូវសុភាទន្សាយគិតថា ៖ បើសិនជាត្រឡប់ទៅផ្ទះ ច្បាស់ជាមនុស្សស្ដីបន្ទោសដោយសារតែបាត់ដំរី ហើយណាមួយខ្លួនជាអ្នកតូចល្អិតផង បើត្រឡប់ដល់ផ្ទះច្បាស់ជាគេវាយមិនខាន ។ បន្ទាប់មកវារត់បែកចេញពីក្របីនោះ ហើយរកកន្លែងលាក់ខ្លួនក្នុងគុម្ពោតព្រៃរហូតមកទល់សព្វថ្ងៃនេះ ។ ឯក្របីវិលត្រឡប់ទៅវិញដោយម្នាក់ឯង ។ ទៅដល់ភូមិមនុស្សសួរ "អាក្របី តើដំរីនៅឯណាទៅ?" ក្របីឆ្លើយឡើង ៖ "វាប្រហែលវង្វេងបាត់ក្នុងព្រៃ ឬមួយត្រូវខ្លាហែកស៊ីអស់ហើយមិនដឹង ។ ខ្ញុំរង់ចាំវានៅឯកន្លែងណាត់ជួបគ្នាយ៉ាងយូរតែមិនឃើញវាមកសោះ ហេតុដូច្នេះទើបខ្ញុំវិលត្រឡប់តែម្នាក់ឯង" ។ បន្ទាប់មកមនុស្សនិយាយទៅក្របីនោះ ៖ "បើអញ្ចឹងចាប់ខ្លួនឯងនេះ ធ្វើជាអាហាររបស់ពួកយើង" ។ វាឮមនុស្សថាយ៉ាងដូច្នោះ ក៏ភ័យខ្លាចជាខ្លាំង ហើយក៏រត់ចូលក្នុងព្រៃក្លាយទៅជាក្របីព្រៃ រហូតមកដល់សព្វថ្ងៃនេះ ៕</td></tr>
<tr><td>៤១</td><td colspan="2">ចូរអ្នកពិភាក្សាជាមួយនឹងគ្រូរបស់អ្នក អំពីមេរៀនចាស់ ដូចជា ម្ហូបអាហារសំរាប់អោយកូនក្មេងនិងមនុស្សធំ រួចនាំគ្នាសរសេរក្នុងតារាងខាងក្រោមនេះ ៖</td></tr>
<tr><td>៤៣</td><td colspan="2">មេរៀនទី៤៦</td></tr>
<tr><td></td><td>បង្រៀនស្រះ</td><td>◌ីរ ◌ែរ</td></tr>
<tr><td></td><td>ពាក្យគន្លឹះ</td><td>នើន ឆ្មា</td></tr>
<tr><td>៤៤</td><td colspan="2">រៀនអាន</td></tr>
<tr><td></td><td colspan="2"><u>ឆ្មាធ្វើមិត្តសំឡាញ់នឹងខ្លា</u>
កាលពីព្រេងនាយ ឆ្មាបាននៅក្នុងព្រៃជាមួយនឹងសត្វដទៃផងដែរ ។ មានថ្ងៃមួយឆ្មាទៅរកចំនីអាហារជាមួយមិត្តសំឡាញ់របស់វាឈ្មោះអាខ្លានៅក្នុងព្រៃ ។ ក្នុងខណៈពេលពួកវាទៅនោះ ពួកវាបានខាំសត្វឈ្លូសមួយក្បាល ។ ខាំរួចហើយខ្លាក៏រិះគិតក្នុងចិត្ត ៖ "តើត្រូវធ្វើយ៉ាងណា ដើម្បីស៊ីសាច់ឈ្លូសនេះបានឆ្ងាញ់?" បន្ទាប់មកខ្លាបញ្ជាឆ្មាអោយទៅយកកាំបិតនៅឯភូមិរបស់មនុស្សរស់នៅ ដេម្បីពន្លះសាច់ឈ្លូសយកទៅហូបនៅឯភូមិ ។ ខ្លានិយាយទៅឆ្មា ៖ "អាឆ្មា! ឥឡូវនេះឯងទៅសុំកាំបិត និងកាផារបស់គេនៅក្នុងភូមិនោះ ដេម្បីដាក់សាច់ឈ្លូសរបស់យើងនេះទៅភូមិ ។ ធ្វើយ៉ាងនោះទើបយើងហូបឆ្ងាញ់មាត់" ។ ឆ្មាឆ្លើយ ៖ "បាទ! បានមិនអីទេ ខ្ញុំនឹងទៅ" ។
ឆ្មាចាក់ចេញពីកន្លែងនោះ ធ្វើដំណើរទៅដល់ភូមិក៏យប់ល្មម ។ វាបានឃើញមនុស្សក្នុងភូមិនោះដេកលក់អស់ហើយ ។ ឆ្មាក៏លួចចូលក្នុងផ្ទះរបស់គេ ស្រាប់តែវាបានឃើញកណ្ដុរ</td></tr>
</table>

<table>
<tr><td></td><td colspan="2">កំពុងតែស៊ីស្រូវនៅក្នុងប៉ុង នៅក្នុងចានឆ្នាំងរបស់មនុស្សច្រើនណាស់ ។ ឆ្មាក៏ដេញខាំកណ្ដុរទាំងនោះ ។ ខាំមួយបានហើយ នៅចង់ខាំមួយទៀត ខាំបានពីរហើយនៅតែចង់បានពីរទៀត ។ អាល័យតែខាំចុះខាំឡើងរហូតមេឃជិតភ្លឺ ។ វាបានឃើញមនុស្សក្រោកពីដេក ។ វាមិនដាច់ចិត្តចាកចេញក៏បង្ហាញខ្លួនអោយមនុស្សឃើញ ។ វាទៅក្បែរមនុស្សហើយនិយាយ ៖ "លោកអ៊ំអើយ! បើអ៊ំចង់វាយខ្ញុំ សូមវាយឥឡូវនេះទៅ បើចង់ដំធាក់ខ្ញុំ សូមដំធាក់ខ្ញុំឥឡូវនេះទៅ បើលោកអ៊ំមិនចង់វាយដំខ្ញុំទេនោះ ខ្ញុំសូមនៅជាមួយលោកអ៊ំផងបានទេ?" អ៊ំនោះសួរ ៖ "តើឯងជានរណា ហើយឈ្មោះអី?" ឆ្មាឆ្លើយ ៖ "ខ្ញុំនេះគឺពួកសត្វរស់នៅក្នុងព្រៃ ។ ខ្ញុំមានឈ្មោះថា អាឆ្មាព្រៃ ។ ដំណើររឿងរបស់ខ្ញុំគឺយ៉ាងនេះណា៎លោកអ៊ំ ៖ ខ្ញុំបានទៅរកចំនីអាហារជាមួយមិត្តរបស់ខ្ញុំម្នាក់ ឈ្មោះថាអាខ្លា ។ ពួកខ្ញុំបានខាំឈ្លូសមួយក្បាល ។ គាត់អោយខ្ញុំសុំកាំបិតនិងកាផារបស់អ៊ំ ដើម្បីពន្លះសាច់ឈ្លូសនោះយកមកហូបនៅក្នុងភូមិនេះ ។ ខ្ញុំដើរមកដល់ភូមិរបស់អ៊ំនេះ ខ្ញុំរកអ៊ុំមិនឃើញសោះ ព្រោះអ៊ំដេកលក់បាត់ទៅហើយ ។ ខ្ញុំមិនហ៊ានដាស់លោកអ៊ំទេ ដូច្នេះខ្ញុំក៏លួចចូលក្នុងផ្ទះរបស់អ៊ំនេះតាមប្រឡោះឆ្កែ ។ មកដល់ក្នុងផ្ទះអ៊ំនេះហើយស្រាប់តែខ្ញុំបានឃើញកណ្ដុរស៊ីស្រូវអ៊ំនៅក្នុងប៉ុង នៅក្នុងចានឆ្នាំងច្រើនណាស់ អាតូចក៏មានអាធំក៏មាន ។ មានអាខ្លះនាំគ្នាស៊ីស្រូវនៅក្នុងជង្រុកឮសូរក្រេចក្រាច់ៗ ណា៎លោកអ៊ំ ។ ខ្ញុំក៏ដេញខាំពួកវា ខាំបានមួយហើយ នៅចង់បានមួយទៀត ខាំបានពីរហើយ នៅចង់បានពីរទៀត គិតតែពីខាំចុះខាំឡើង រហូតដល់មេឃជិតភ្លឺ ក៏បានជួបនឹងអ៊ំតែម្ដង" ។ អ៊ំនោះនិយាយ ៖ "អ្ហូ! បើឯងចង់រស់នៅជាមួយយើងមែននោះ មិនអីទេ ខ្ញុំអោយឯងនៅ" ។ ដូច្នេះឆ្មាក៏រស់នៅកន្លែងនោះតែម្ដង លែងត្រឡប់ទៅជួបមិត្តខ្លាទៀតហើយ" ។
លុះដល់ប្រាំមួយថ្ងៃក្រោយមក ខ្លាស្វែងរកឆ្មា ។ ពួកវាបានជួបគ្នានៅក្នុងព្រៃមួយ ។ ខ្លាក៏និយាយទៅឆ្មា ៖ "អាឆ្មា! តើខ្ញុំបានអោយឯងទៅសុំអ្វី? ខ្ញុំបានអោយឯងទៅសុំកាំបិតនិងកាផារបស់គេ" ឆ្មាឆ្លើយ ៖ "អើ! មិត្ត! ឯងនិយាយត្រឹមត្រូវហើយ ឥឡូវនេះសុំចែកកន្លែងរស់នៅហើយណា៎! ឯងនៅក្នុងព្រៃ ឯខ្ញុំវិញរស់នៅក្នុងភូមិ បើឯងមានរឿងអ្វីមួយ ឯងរត់មកពឹងខ្ញុំ បើខ្ញុំមានរឿងអ្វីមួយខ្ញុំនឹងរត់ទៅពឹងឯង យ៉ាងម៉េចដែរ?" ខ្លានិយាយ ៖ "បើអីចឹង ខ្ញុំសុំនៅជាមួយឯងដែរ ប្រហែលគេអោយដែរឬអត់ហ្ន៎!" ឆ្មាឆ្លើយ ៖ "មិនបានទេណា៎មិត្ត ឯងនេះល្មោភស៊ីណាស់ គេមិនអោយឯងរស់នៅជាមួយពួកគេទេ" ។ ក្រោយពេលពួកវានិយាយគ្នាហើយ ពួកវានាំគ្នាចែកផ្លូវដើររៀងៗខ្លួន ។ ឆ្មាវិលត្រឡប់ទៅរស់នៅជាមួយមនុស្សក្នុងភូមិ រីឯខ្លាវិញក៏ត្រឡប់ទៅរស់នៅក្នុងព្រៃរហូតតទៅ ៕
<u>សំនួរ</u>
-ឆ្មានិងខ្លាដើររកចំណីជាមួយគ្នានៅក្នុងព្រៃ តើពួកវាបានខាំចំណីអ្វីខ្លះ?
-តើសត្វខ្លាបញ្ជាអោយឆ្មាទៅយករបស់អ្វីខ្លះនៅក្នុងភូមិរបស់មនុស្ស?</td></tr>
<tr><td>៤៧</td><td>រៀនសរសេរ</td><td>-ឆ្មារបស់មីងដេញខាំកូនសារិការកែវរបស់ខ្លួន ។
-ពិលផ្ទះរបស់នើនខ្សោយភ្លើងហើយ ។</td></tr>
</table>

៤៨	ចូរជ្រើសរើសស្រៈ " ◌ីរ " សរសេរប្រកបអោយបានបីពាក្យខាងក្រោមនេះ ៖
៤៨	ចូរជ្រើសរើសបីពាក្យខាងលើ សរសេរតែងជាប្រយោគអោយបានបីខាងក្រោមនេះ ៖
៤៨	ចូរជ្រើសរើសស្រៈ " ែ◌រ " សរសេរប្រកបអោយបានបីពាក្យខាងក្រោមនេះ ៖
៤៨	ជ្រើសរើសបីពាក្យខាងលើ សរសេរតែងជាប្រយោគអោយបានបីខាងក្រោមនេះ ៖
៤៩	គ្រូអានអត្ថបទអោយសិស្សស្តាប់
	ចំណីអាហារទាំងបីក្រុម ចំណីអាហារទាំងបីក្រុមខាងក្រោមនេះ សំរាប់ការលូតលាស់ និងសុខភាពល្អ ។ ១ ចំណីអាហារសាងសង់ ៖ ជាតិសាច់ ឱទាហរណ៍ដូចជា៖ ត្រី កង្កែប ក្តាម កំពឹស ស៊ុត ឬ សណ្តែកផ្សេងៗ ។ ២ ចំណីអាហារថាមពល ៖ ក- ចំណីអាហារថាមពលខ្ពស់៖ ខ្លាញ់ជ្រូក ខ្លាញ់ត្រី ស្ករអំពៅទឹកឃ្មុំ ចេកណាំវ៉ា ដូង ខ- អាហារមូលដ្ឋាន៖ ពោត អង្ករ បបរស នំបញ្ចុកជំឡូង ផ្សេងៗ ។ ៣ អាហារការពាររាងកាយហើយនិងមានវីតាមីនច្រើន ៖ ស្ពៃ ផ្ទី ត្រួយល្ពៅ ត្រកួន ស្លឹកមានពណ៌បៃតងផ្សេងៗ ដែលធ្លាប់ញាំ ផ្លែល្ពៅល្ហុងទុំ ប៉េងប៉ោះ ផ្លែក្រូច ផ្លែផ្សេងៗ ។ **សំនួរពិភាក្សា** -តើមានម្ហូបអាហារប៉ុន្មានមុខ ដើម្បីអោយរាងកាយរបស់យើងឆាប់លូតលាស់និងមានសុខភាពល្អ? អ្វីខ្លះ?
៥១	**មេរៀនទី៤៧**
	បង្រៀនស្រៈ: | េ ◌ា
	ពាក្យគន្លឹះ: | ខ្លាឃ្មុំ ខ្លា
៥២	រៀនអាន
	ទន្សាយប្រើល្បិចដាក់ខ្លា កាលពីព្រេងនាយមានខ្លាមួយធ្លាប់ដើរខាំដំរី ។ ដំរីនោះនៅមួយហ្វូងមានប្រាំពីរក្បាល ។ ថ្ងៃមួយខ្លាបានខាំដំរីនៅក្បែរគុម្ពឫស្សីមួយ ។ ខាំមួយស៊ីអស់ ខាំពីរស៊ីអស់ ខាំស៊ីរហូតដល់ប្រាំមួយក្បាល ។ ប៉ុន្តែនៅសល់ដំរីឈ្មោលមួយក្បាលដែលរត់រួចពីក្រញាំខ្លានោះ ។ ដំរីមួយក្បាលនោះគិតថាត្រូវធ្វើយ៉ាងម៉េច ទើបខ្លួនបានរួចផុតពីមាត់ខ្លាកំណាច ។ ដំរីក៏នឹកឃើញដល់ទន្សាយ ។ គិតរួចហើយដំរីទៅរកសុភាទន្សាយភ្លាម ។ វាចេះតែដើរផ្តេសផ្តាសពេញព្រៃ ក៏ជំពប់ជើងនឹងគុម្ពោតស្មៅ ។ ពេលនោះស្រាប់តែទន្សាយស្ទុះចេញពីគុម្ពោតស្មៅលោតផ្លោតៗ ។ ទន្សាយសួរ៖ "អ្នកណាដើរហ្នឹងគ្មានភ្នែកទេអី? រំខានគេកំពុងតែដេកពួនអត់ដឹងអីមែន "។ ពួដូច្នោះដំរីឆ្លើយ៖ "ខ្ញុំទេពូ "។ ទន្សាយសួរទៅដំរី៖ "មានរឿងអី

<table>
<tr><td></td><td colspan="2">បានជាឯងដើរជាន់កន្លែងខ្ញុំដែលកំពុងដេកពួនដូច្នេះ? «មានរឿងហេតុដែរ បានជាខ្ញុំរត់ព្រោះខ្លាដេញខាំខ្ញុំណាំពូ! ខាំគ្នាខ្ញុំអស់ប្រាំមួយក្បាលហើយ នៅសល់តែខ្ញុំមួយទេណាំពូទន្សាយអើយ! ថ្ងៃនេះវាបកមកខាំខ្ញុំទៀតហើយ សូមពូជួយខ្ញុំផង" ។ ទន្សាយឆ្លើយ ៖ "ទៅខ្លាចអីអីចឹងៗខ្លួនរបស់ឯងធំប៉ុនណាប៉ុនណី ឯខ្លាតូចជាងឯងទេ រឿងអីឯងត្រូវខ្លាច" ។ ដំរីតបវិញ ៖ "កុំនិយាយលេងអអីចឹងណាំពូ! សូមពូជួយខ្ញុំមែនណាំ! ថ្ងៃនេះតែម្ដងដែលវាមកខាំខ្ញុំ" ។ ទន្សាយតបវិញ ៖ "កុំព្រួយអោយសោះ ឥឡូវឯងត្រឡប់ទៅកន្លែងសិន មួយស្របក់ទៀតទើបខ្ញុំតាមឯងពីក្រោយ» ។ បន្តិចក្រោយមកខ្លាក៏មករកដំរីនៅកន្លែងគុម្ពឫស្សី ដែលវាធ្លាប់ខាំដំរីពីមុនៗមក ។ ទន្សាយបានរិះរកមធ្យោបាយដើម្បីជួយដំរី ។ វាគិតថា បើសិនជាវាមិនជួយដំរីច្បាស់ជាស្លាប់មិនខាន ។ គិតរួចហើយទន្សាយក៏ទៅកន្លែងដំរី ។ ទន្សាយនិយាយប្រាប់ដំរី ៖ "ដំរីឯងចាំធ្វើតាមពាក្យខ្ញុំណា " ។ ដំរីសួរទន្សា ៖ "តើយើងត្រូវធ្វើយ៉ាងម៉េច?" ទន្សាយឆ្លើយ ៖ "បើខ្លាមកដល់ខ្ញុំធ្វើជាហក់ខាំក្បាលដំរីឯង ហើយដំរីឯងធ្វើជាដួលស្លាប់មួយសន្ទុះ រួចហើយខ្ញុំចុះទៅទាញស្លឹកត្រចៀកដំរីឯង ។ ពេលនោះដំរីឯងធ្វើជាខិតទៅមុខ ។ ដំរីឯងត្រូវធ្វើតាមពាក្យខ្ញុំទាំងអស់ណាំ" ។

ពេលនោះខ្លាក៏មកដល់កន្លែងល្មម ។ ទន្សាយហក់ឡើងលើក្បាលដំរី រួចធ្វើជាខាំដំរីនោះគ្រវីគ្រវាត់ ។ ដំរីធ្វើជាស្រែក ហើយធ្វើជាដួលលើដី ។ ទន្សាយចុះមកចាប់ទាញស្លឹកត្រចៀកដំរីនោះអូសឡើងលើ ឯដំរីធ្វើជាខិតឡើងលើទន្សាយទាញចុះក្រោម ក៏ធ្វើជាខិតចុះក្រោមតាមតែទន្សាយណែនាំ ។ ខ្លាឃើញទន្សាយធ្វើទៅលើដំរីដូច្នោះ ក៏នឹកក្នុងចិត្ត ៖ "យី! ម្នាក់នោះអីខ្លាំងម្ល៉េះហ្ន៎! ខ្លួនវាតូចសោះ" ។ ទន្សាយនិយាយ ៖ "ហឹស! ដំរីនេះតូចណាស់ អញស៊ីមិនស្ទៀបជើងធ្មេញសោះ បើបានខ្លាមួយទៀតស៊ីទើបឆ្អែត" ។ ខ្លាឮទន្សាយថាដូច្នោះរត់ចូលក្នុងព្រៃបាត់ទៅ ។

ចំណែកឯដំរីវិញ ឃើញខ្លារត់ចូលក្នុងព្រៃបាត់ដូនោះ អរក្នុងចិត្តជាខ្លាំងហើយអរគុណទន្សាយដែលបានជួយវា ។ ក្រោយមកដំរីនឹងទន្សាយបែកចេញពីគ្នា ត្រឡប់ទៅនៅកន្លែងវិញរៀងៗខ្លួន ៕

<u>សំនួរ</u>
១-តើហ្វូងដំរីមួយនោះ មានប៉ុន្មានក្បាល?
២-តើខ្លាបានខាំហ្វូងដំរីនោះ អស់ប៉ុន្មានក្បាល? នៅសល់ប៉ុន្មានក្បាល?
៣-តើសត្វមួយណាដែលបានជួយដល់សត្វដំរី រួចជីវិតពីក្រញាំខ្លា?</td></tr>
<tr><td>៥៦</td><td>រៀនសរសេរ</td><td>-នើនកំពុងតែជំរះស្មៅចំការជាមួយនឹងចបជីក ។
-ខ្លាដេញខាំកូនខ្លាឃ្មុំរបស់នើន ។</td></tr>
<tr><td>៥៧</td><td colspan="2">ចូរជ្រើសរើសស្រៈ " េ □ ា " សរសេរប្រកបអោយបានបួនពាក្យខាងក្រោមនេះ ៖</td></tr>
<tr><td>៥៧</td><td colspan="2">ជ្រើសរើសបួនពាក្យខាងលើ សរសេរតែងអោយបានបួនប្រយោគខាងក្រោម ៖</td></tr>
</table>

៥៩	**មេរៀនទី៤៨**	
	បង្រៀនស្រះ	ិ
	ពាក្យគន្លឹះ	គេង កាច់បំបាក់
៦០	រៀនអាន	
	ម្ដាយពិចមានជំងឺគ្រុនចាញ់ នៅយប់មួយ ឪពុកម្ដាយរបស់បងពិច នាំគ្នាឡើងគេងលើគ្រែ ដោយមិនបានចងមុង ។ យប់នោះមានមូសជាច្រើនខាំសាច់ឪពុកម្ដាយរបស់គាត់ ។ មួយអាទិត្យក្រោយមកម្ដាយរបស់គាត់ទៅស៊ីឈ្នួលវាយថ្មអោយគេ បានលុយដើម្បីទិញអំបិលហូប ។ ដល់កន្លែងវាយថ្ម ម្ដាយរបស់គាត់ចាប់ផ្ដើមមិនស្រួលក្នុងខ្លួន ចេះតែស្រៀវឆ្អឹងខ្នង ហើយមិនអាចវាយថ្មជាមួយនឹងក្រុមកម្មករបានទេ ។ គាត់ក៏ត្រឡប់មកដល់ផ្ទះវិញ ។ គាត់គ្រុនញាក់កាន់តែខ្លាំងឡើងៗ ។ គាត់អោយកូនប្រុសរបស់គាត់ ទៅរកអុសមកបង្កាត់ភ្លើងដើម្បីកំដៅ ។ កូនប្រុសរបស់គាត់ក៏ទៅកាច់មែកឈើងាប់នៅក្បែរផ្ទះរបស់ខ្លួនយកមកធ្វើអុស ។ បន្ទាប់មកកូនគាត់យកអុសទាំងនោះមកបង្កាត់ភ្លើងអោយម្ដាយអង្គុយអាំងអោយបាត់រងា ។ ទោះបីម្ដាយរបស់គាត់បានអង្គុយអាំងភ្លើងយ៉ាងណាក៏ដោយ ក៏ជំងឺគ្រុនញាក់ក្នុងខ្លួនរបស់គាត់នៅតែមិនជាដដែល ។ ភ្ញាក់ឡើងព្រឹកថ្ងៃស្អែក ឪពុករបស់បងពិចជូនម្ដាយរបស់គាត់ទៅមន្ទីរពេទ្យ ។ មកដល់មន្ទីរពេទ្យ ឪពុករបស់បងពិចអោយគ្រូពេទ្យពិនិត្យ មើលជំងឺប្រពន្ធរបស់គាត់ ។ អ្នកគ្រូពេទ្យជោះឈាមម្ដាយរបស់បងពិច រួចយកទៅពិនិត្យ ឃើញមានជំងឺគ្រុនចាញ់ពីរខ្វែង ។ បន្ទាប់មកអ្នកគ្រូពេទ្យអោយថ្នាំទៅអោយប្រពន្ធរបស់គាត់លេប ។ អ្នកគ្រូពេទ្យផ្ដែផ្ដាំអ្នកទាំងពីរដេកនៅពេលយប់ សូមចងមុងអោយល្អជុំជិត កុំអោយមូសខាំ ។ បើសិនជាមូសបានខាំហើយវា នឹងនាំឈាមកើតជំងឺគ្រុនចាញ់ភ្លាម ។ ក្រោយមកពួកគេវិលត្រឡប់មកផ្ទះវិញ ហើយធ្វើតាមពាក្យបណ្ដាំរបស់អ្នកគ្រូពេទ្យ ។ ក្នុងគ្រួសាររបស់ពួកគេលែងមានជំងឺគ្រុនចាញ់មកយាយីអាយុជីវិតគេទៀតឡើយ ៕	
៦១	រៀនសរសេរ	-នើនមិនអាចគេងក្នុងព្រៃបានឡើយ ។ -នើនមិនអាចកាច់បំបាក់មែកឈើបានទេ ។
៦២	ចូរជ្រើសរើសស្រះ " ិ " សរសេរប្រកបអោយបានបីប្រយោគ ៖	
៦២	ជ្រើសរើសបីពាក្យដែលបានសរសេរខាងលើ ហើយតែងអោយបានដប់ប្រយោគ ៖	
៦៣	រៀនអាន	
	អំពីជំងឺគោក្របី សត្វគោក្របីមានសារៈសំខាន់ខ្លាំងណាស់ សំរាប់បំរើផលប្រយោជន៍របស់មនុស្សយើង ។ សត្វគោក្របីតែងតែជួយកំលាំងនិងបំរើផលប្រយោជន៍យើងដូចជា ៖ ភ្ជួរស្រែចំការ ទឹមរទេះ	

	កាប់យកសាច់ស៊ី នៅពេលមានកម្មវិធីរៀបការកូនកំលោះកូនក្រមុំ ឬកាប់យកឈាមវាលាង អបីជំនឿផ្សេងៗ និងអាចយកវាទៅលក់បានប្រាក់ច្រើនទៀតផង ។ ប្រជាជនភាគច្រើនចិញ្ចឹមគោក្របី ។ ប៉ុន្តែការចិញ្ចឹមគោក្របីរបស់ពួកគេជួបប្រទះនូវជំងឺសត្វដែលធ្វើអោយសត្វរបស់ទាំងនោះឈឺឬងាប់ជាច្រើន ។ បើគោក្របីងាប់យ៉ាងដូច្នេះ យើងគ្មានគោក្របីឯណា សំរាប់មកជួយជាកំលាំងដល់យើងឡើយ ហើយធ្វើអោយយើងសោកស្តាយយ៉ាងខ្លាំង ។ បើសិនជាយើងយល់ដឹងពីជំងឺនោះ យើងនិងងាយស្រួលការពារមិនអោយសត្វរបស់យើងឆ្លងជំងឺបាន ។ ជំងឺគោក្របីនៅក្នុងប្រទេសរបស់យើងនេះមាន ៖ ១- គឺជំងឺសាទឹក ២- គឺជំងឺបូសខ្យល់ ៣- គឺជំងឺអុតក្តាម ។ ជំងឺសាទឹក គឺជាជំងឺមួយដែលឆាប់កើតមាននៅលើសត្វក្របីនិងកូនរបស់វា នៅរដូវវស្សា ។ រោគសញ្ញារបស់វា គឺពិបាកដកដង្ហើម ចេញទឹកមាត់ ហើមក ។ ជំងឺនេះឈឺត្រឹមរយៈពេលតែពីរថ្ងៃប៉ុណ្ណោះ ។ ក្រោយមកវានឹងងាប់ភ្លាមតែម្តង ។ ចំណែកការឆ្លងរាលដាលរបស់វាវិញគឺឆាប់រហ័សណាស់ពីក្របីឈឺទៅក្របីដែលមិនឈឺ ។ បើសិនក្នុងភូមិណាមួយកើតមានជំងឺនេះហើយ ក្រោយមកវានឹងងាប់ភ្លាម ។ តែផ្ទុយទៅវិញបើសិនយើងឃើញជំងឺនេះកើតលើសត្វក្របីរបស់យើង សូមចាក់ថ្នាំតេត្រាសេគ្លីនសំរាប់ព្យាបាលវា ។ ចំណែកជំងឺបូសខ្យល់វិញ វាឆាប់កើតមានលើសត្វគោ ជាពិសេសគឺនៅក្នុងខេត្តមណ្ឌលគីរី ។ ចាប់ផ្តើមចេញរោគសញ្ញា ៖ -ក្តៅខ្លាំង -ឈឺជើងម្ខាង ហើយនិងហើម ។ បើយើងស្ទាបច្របាច់វា ហាក់បីដូចមានខ្យល់នៅខាងក្នុង ។ បើសត្វគោក្របីមួយណាកើតជំងឺបូសខ្យល់នេះ វាឈឺរយៈពេលពីរថ្ងៃប៉ុណ្ណោះ រួចក៏ងាប់ ។ ជំងឺនេះវាមិនឆ្លងរាលដាលដូចជំងឺសាទឹកទេ តែវាកើតជំងឺនេះលើគោជាច្រើនក្នុងពេលតែមួយ ។ បើយើងឃើញគោកើតមានជំងឺនេះ សូមចាក់ថ្នាំពែនស្រ៊ីប សំរាប់ព្យាបាលវាអោយជា ។ អំពីជំងឺអុតក្តាម ជំងឺនេះជាជំងឺឆ្លងរាលដាល ។ វាតែងតែងកើតមានលើសត្វគោនិងក្របី ។ វាឆ្លងរាលដាលពីសត្វមួយទៅសត្វមួយទៀត ។ រោគសញ្ញា -រលាកអណ្តាត និងដំបៅក្រចក ។ គោក្របីដែលកើតមានជំងឺអុតក្តាមនេះ មិនអាចងើបពីដេកដើរទៅស៊ីចំនីបានទេ ។ វាស្គមស្គាំងដោយសារតែវាដើរស៊ីចំនីមិនបាន ។ ជំងឺនេះជាជំងឺកាចសាហាវណាស់ ។ ជំងឺនេះបើកើតលើកូនគោវិញ កូនគោនោះវានឹងងាប់ភ្លាម បើកើតលើមេគោធើម កូនគោក្នុងពោះនោះនឹងរលូតតែម្តង ។ បើជំងឺអុតក្តាមបានកើតលើគោក្របីរបស់យើងហើយ វានឹងឆ្លងរាលដាលគ្រប់គោក្របីរបស់យើងក្នុងភូមិតែមួយ ។ ជំងឺអុតក្តាមនេះយើងគ្មានថ្នាំសំរាប់ព្យាបាលបានទេ ។ តែយើងអាចការពារនិងអនាម័យវាបាន ដូចជា យកសាប៊ូដុសលាងក្រចកវាអោយបានរាល់ថ្ងៃ និងស្វែងរកចំនីខ្ចីៗអោយវាស៊ី ។ យើងធ្វើបែបនេះគឺដើម្បីអោយកុំអោយវាស្គមហើយនឹងឆាប់ជាដំបៅក្រចករបស់វាដែរ ។ សំរាប់ជំងឺទាំងបីនេះ យើងមានថ្នាំសំរាប់ការពារ ។ យើងអាចចាក់ថ្នាំការពារគោក្របីមុនពេលវាកើតមានជំងឺ ។ បើយើងចាក់ថ្នាំការពារបែបនេះ មេរោគមិនអាចប៉ះពាល់ដល់

	សុខភាពសត្វរបស់យើងបានទេ ។ ថ្នាំនេះយើងអាចរកទិញនៅមន្ទីរកសិកម្មបាន ឬយើងអាចសួរពេទ្យសត្វក្នុងភូមិ បើសិនជាមានពេទ្យសត្វភូមិ ។ បើសិនជាមាននរណាម្នាក់ចង់យល់ដឹងអំពីជំងឺគោក្របី ជ្រូក មាន់ ទា ឆ្កែ សូមអោយគាត់ទៅទាក់ទងនឹងបុគ្គលិកនៅមន្ទីរកសិកម្ម ឬក៏គ្រូពេទ្យសត្វនៅក្នុងភូមិរបស់យើង ។ ពេទ្យសត្វដែលនៅក្នុងភូមិរបស់យើងនោះបានឆ្លងការបណ្តុះបណ្តាលរួចទៅហើយ ។ ដូច្នេះមានតែពួកគេទេ ទើបអាចជួយព្យាបាលបង្ការជំងឺគោក្របីរបស់យើងអោយល្អប្រសើរបាន ៕ **<u>សំនួរ</u>** ១-តើនៅក្នុងប្រទេសរបស់យើងនេះ មានជំងឺកើតលើគោក្របីប្រមាណប្រភេទ? ២-តើរោគសញ្ញាជំងឺសាទឹកគឺអ្វីខ្លះ? តើវាឈឺរយៈពេលប៉ុន្មានទើបងាប់? ៣-តើជំងឺសាទឹកនេះច្រើនកើតលើសត្វនៅពេលណា? ៤-តើរោគសញ្ញាជំងឺបូសខ្យល់អ្វីខ្លះ? វាឈឺប៉ុន្មានថ្ងៃទើបងាប់? តើមានថ្នាំព្យាបាលឬទេ? ៥-តើរោគសញ្ញាជំងឺអុតក្តាមអ្វីខ្លះ? តើយើងត្រូវធ្វើយ៉ាងណា ដើម្បីព្យាបាលសត្វយើងអោយជាពីជំងឺអុតក្តាមបាន? ៦-តើជំងឺទាំងនេះបានប៉ះពាល់ដល់សុខភាពសត្វរបស់យើងយ៉ាងដូចម្តេច? តើយើងគួរទប់ស្កាត់ដូចម្តេចខ្លះ? ៧-តើជំងឺទាំងនេះ យើងមានថ្នាំការពារដែរឬទេ? ៨-តើយើងគួររកទិញថ្នាំការពារ នៅទីកន្លែងណា?
៦៩	**មេរៀនទី៤៩**
	បង្រៀនព្យញ្ជនៈ | ខ
	ពាក្យគន្លឹះ | ខែ
៧០	រៀនអាន
	<u>សកម្មភាពការងារជនជាតិព្នងក្នុងមួយឆ្នាំ</u> ក្នុងមួយឆ្នាំមានដប់ពីរខែ ក្នុងមួយខែមានបួនអាទិត្យ ។ ក្នុងមួយអាទិត្យមានប្រាំពីរថ្ងៃ ក្នុងមួយថ្ងៃមានម្ភៃបួនម៉ោង ។ ក្នុងមួយឆ្នាំមានបីរយហុកសិបប្រាំថ្ងៃ ក្នុងមួយខែ ជួនមានម្ភៃប្រាំបីថ្ងៃ សាមសិបថ្ងៃ និងសាមសិបមួយថ្ងៃ ។ ប្រជាជនជនជាតិព្នង តែងតែធ្វើស្រែនិងចំការ ។ ប៉ុន្តែមានមនុស្សភាគច្រើនធ្វើចំការជាជាងធ្វើស្រែ ។ ការរស់នៅរបស់ពួកគេ គឺពឹងផ្អែកទៅលើស្រែចំការតែមួយមុខទេ ។ ក្នុងខែនីមួយៗ ពួកគេខំប្រឹងធ្វើការងារ ដើម្បីជីវភាពក្នុងគ្រួសារ ដូចជា៖ ធ្វើការក្នុងចំការ ធ្វើការក្នុងស្រែ ឬ ឃ្វាលដំរី គោ ក្របី និងចិញ្ចឹម សត្វ ជ្រូក ឆ្កែ ឆ្មា ឬ ត្បាញកាផា ត្បាញចង្កេរ ឈ្នាង ជាដើម ។ សកម្មភាពការរស់នៅពួកគេរាល់ថ្ងៃ គ្មានការរីកចំរើនបន្តិចទេ នៅដដែលៗ គិតតែពីប្រកបមុខរបរធ្វើស្រែនិងចំការ ។ ការងារកសិករធ្វើស្រែនិងចំការរបស់ពួក

ក៏មិនពិតប្រាកដថាជាជំនាញដូចអ្នកដទៃទេ ។ ជួនពួកគេធ្វើស្រែនិងចំការទទួលផលបានច្រើនជួនពួកគេធ្វើទៅមិនបានទទួលផលច្រើន ក៏សុខចិត្តស៊ីអត់ស៊ីឃ្លានពេញមួយឆ្នាំនោះទៅ ។ អ្នកមានដំរីនិងគោក្របីច្រើន មានអ្នកស៊ីឈ្នួលធ្វើស្រែចំការ ក្នុងចំណោមពួកគេនោះគេហៅថាជាអ្នកមានហើយ ។

ចាប់ផ្តើមខែពីរ ជនជាតិព្នងទាំងអស់នាំគ្នារៀបចំប្រដាប់ប្រដា ធ្វើស្រែចំការ និងពិភាក្សាគ្នាពីការងារដែលត្រូវធ្វើ ដូចជាជំរះចំការចាស់ ឬក៏កាប់ចំការថ្មី ។ អ្នកខ្លះទៀតនាំគ្នាទៅរកម្ហូបអាហារក្នុងព្រៃឬរកអ្វីដែលគេត្រូវការ ។ ចូលដល់ខែបួនពួកគេនាំគ្នាដុតចំបើងក្នុងចំការចាស់នោះចោល និងចំការថ្មីផងដែរ ។ រួចនាំគ្នាប្រវាស់ដៃធ្វើការជាមួយគ្នានៅក្នុងចំការទាំងនោះទៅ ។ ចូលដល់ខែប្រាំ ឬពាក់កណ្តាលខែប្រាំ ពួកគេនាំគ្នាដាំស្រូវក្នុងចំការចាស់ព្រមទាំងនាំគ្នាប្រមូលមែកឈើដុតក្នុងចំការថ្មីដែរ ។ មានអ្នកខ្លះបានចោលចំការចាស់ស្វែងរកកាប់ចំការថ្មី ។ អ្នកនោះក៏ប្រវាស់ដៃគ្នាដាំស្រូវជាមួយអ្នកប្រើចំការចាស់ដែរ ដើម្បីបានគ្នាច្រើនមកជួយដាំស្រូវក្នុងចំការថ្មី ។ ចំណែកឯអ្នកធ្វើស្រែវិញ ពួកគេនាំគ្នាលើកភ្លឺស្រែនិង ភ្ជួររាស់ជាមួយនឹងគោក្របីតាមស្រែ ។

ឆ្លងចូលខែប្រាំមួយដល់ខែប្រាំពីរ ពួកគេនាំគ្នាដាំស្រូវក្នុងចំការថ្មី និង ស្ទូងស្រូវក្នុងស្រែរបស់ពួកគេផងដែរ ។ ចូលខែប្រាំបីដល់ខែប្រាំបួន ក្រុមយុវវ័យ ឬក្មេងជំទង់ ប្រវាស់ដៃគ្នាជួយជំរះសំអាតស្មៅគុម្ពស្រូវតាមចំការនីមួយៗ និងកាប់ដើមឈើឬស្រាស់ជុំវិញចំការទាំងនោះកុំអោយមានសត្វណាមួយមកស៊ីដំណាំដាំដុះក្នុងចំការ ។ មនុស្សខ្លះនាំគ្នាទៅដាក់អន្ទាក់ក្នុងព្រៃ ដាក់ទ្រូតាមអូរនានា បានសាច់បានត្រីជាអាហារ ។ ចូលដល់ខែដប់ ពួកគេនាំគ្នាបូតស្រូវស្រាលដែលទុំមុនគេនិងទន្ទឹងរង់ចាំមើលស្រូវដែលមិនទាន់ទុំក្នុងចំការនោះ កុំអោយសត្វមួយណាមកបំផ្លិចបំផ្លាញមុនវាទុំនោះឡើយ ។ ចូលដល់ខែដប់មួយពួកគេចាប់ផ្តើមនាំគ្នាបូតស្រូវប្រមូលពីការចំការមកដាក់ក្នុងជង្រុក រហូតដល់ខែដប់ពីរ ទើបពួកគេប្រមូលអស់ស្រូវពីចំការ ។ ចំណែកអ្នកខ្លះដែលបានធ្វើចំការធំជាងគេ ប្រមូលស្រូវរហូតដល់ខែមួយ ទើបអស់ពីចំការព្រោះអីការបូតស្រូវមួយក្ទួរៗ មិនមែនលឿនដូចយើងច្រូតហើយនិងបោកនោះទេ ។ ចំណែកអ្នកដែលធ្វើស្រែវិញ ចាប់ផ្តើមពីខែដប់មួយ ពួកគេនាំគ្នាច្រូតស្រូវប្រមូលពូនដាក់មួយកន្លែង ។

ឆ្លងចូលខែមួយរហូតដល់ខែពីរ ពួកគេកំពុងតែប្រមូលផលពីស្រែយ៉ាងសកម្ម ។ នៅពេលថ្ងៃពួកគេធ្វើកិច្ចការផ្សេងៗ នៅពេលយប់ពួកគេបោកបែនស្រូវតាមវាលស្រែ ។ ពីព្រលប់មានមនុស្សម្នាក់ពីគ្រួសារមួយ ដើរទៅហៅគ្នាតាមផ្ទះនីមួយៗក្នុងភូមិ ដើម្បីអោយជួយបោកបែនស្រូវរបស់គាត់ ។ ចំណែកមនុស្សឯទៀតក្នុងចំណោមគ្រួសារនោះ នាំគ្នារៀបចំម្ហូបអាហារនិងរបស់របរ ដូចជា ៖ ជ្រូក ឆ្កែ អង្ករ ចាន ឆ្នាំង ស្លាបព្រា វែក ស្រាពាង ពីរបីពាងនាំគ្នាស្ពាយទៅស្រែក្បែរពំនូកស្រូវនោះ ។ បន្ទាប់មកនាំគ្នាដុតរោលជ្រូកទាទាំងនោះធ្វើជាអាហារទទួលទានពេលល្ងាច ។ ទៅដល់កន្លែងពំនូកស្រូវក្នុងស្រែនោះហើយ មានមនុស្សម្នាក់

	ទៅកាច់ស្លឹកឈើ ដើម្បីទ្រាប់មាត់ពាងស្រាមកផឹក ។ ម៉ោងប្រាំពីរទៅម៉ោងប្រាំបីយប់ នៅក្នុងស្រែក្បែរពំនូកស្រូវ មានមនុស្សមកជួបជុំគ្នា ។ ម្ចាស់ស្រែក៏ទទួលពួកគេអោយពិសាបាយពេលល្ងាច ។ នៅពេលពួកគេជួបជុំគ្នាអស់ហើយ ពួកគេរាប់ចំនួនមនុស្សយុវវ័យប្រុសស្រីមានប៉ុន្មាន មនុស្សចាស់ប្រុសស្រីមានប៉ុន្មាន ចែកគ្នាជាពីរក្រុម ។ ក្រុមយុវវ័យបោកបែនមុន ក្រុមចាស់ៗ នាំគ្នាអង្គុយពិសាស្រាពាងនៅលើចំបើង ។ ក្រោយមកក្រុមចាស់ៗ ជាអ្នកបោកបែនស្រូវម្តង ។ ឯក្រុមយុវវ័យនាំគ្នាពិសាស្រាពាងនៅលើចំបើងវិញ ។ ពីរក្រុមនោះផ្លាស់ប្តូរគ្នាបោកស្រូវពីពំនូករហូតទាល់តែអស់ នៅពេលមេឃភ្លឺស្រាងៗ ។ ក្រោយមកពួកគេនាំគ្នាវិលត្រឡប់មកផ្ទះរបស់គេរៀងៗខ្លួន ៕ **<u>សំនួរ</u>** ១-ក្នុងមួយឆ្នាំមានប៉ុន្មានខែ? ក្នុងមួយខែប៉ុន្មានថ្ងៃ? ២-តើជនជាតិព្នងក្នុងមួយខែៗបានធ្វើអ្វីខ្លះ? ៣-តើខែមួយណាដែលពួកគេនាំគ្នាដាំស្រូវក្នុងចំការនិងស្ទូងស្រូវក្នុងស្រែ?	
៧៤	រៀនសរសេរ	-ខែនេះក្របីរបស់នើនងាប់អស់មួយ ។ -ផ្តិលរបស់នើនអណ្តែតជាប់នឹងដើមឫស្សី ។
៧៥	ចូរសរសេរ ជីវប្រវត្តិ ឬ តែងអត្ថបទផ្សេងៗ ដូចជា៖ ការជិះក្របីដើរលេងនៅក្នុងតារាង៖	
៧៧	**មេរៀនទី៥០**	**មេរៀនរំលឹកឡើងវិញ**
៧៧	រៀនអាន	
	<u>រឿងអំពីសត្វមៀម</u> កាលពីព្រេងនាយ មានសត្វស្លាបមួយហៅថាសត្វមៀម បានរៀបការជាមួយលោកខែ ។ ពួកវារស់នៅជាមួយគ្នានៅលើមេឃអស់រយៈពេលដ៏យូរលង់ណាស់មកហើយ ប៉ុន្តែពួកវាគ្មានកូន សោះ ។ មានថ្ងៃមួយសត្វមៀមនោះនិយាយកាន់ទៅលោកខែ៖ "តើការរស់នៅរបស់លោកខែឯងនេះយ៉ាងម៉េចទៅ? ពេលខ្លះមាឌលោកតូច ពេលខ្លះមាឌលោកធំ ហើយគិតតែពីធ្វើដំណើរកំសាន្តជុំវិញផែនដីជារៀងរាល់ថ្ងៃ ។ លោកឯងនេះគ្មានរវីរវល់ជួយធ្វើការអោយខ្ញុំសោះ" លោកខែឆ្លើយ៖ "ហេតុអ្វីបានជាអូនឯងថាអោយបងយ៉ាងនេះ? អូនមិនដឹងទេថា បងគឺជាអ្នករត់តាមផែនដីទេឬអី? បងធ្វើបែបនេះគឺដើម្បីបំភ្លឺផែនដីទាំងមូលអាចដើររកចំនីអាហារបាន មិនមែនបងធ្វើដំណើរដើម្បីបង្អួតពួកស្រីៗក្រមុំនៅលើផែនដីនោះ" ។ សត្វមៀមនិយាយទៀត៖ "ទេ! លោកឯងនេះមិនមែនដូចពាក្យលោកឯងថានោះទេ! លោកឯងនេះគឺបិសាចព្រៃ! លោកឯងធ្វើដំណើរឥតឈប់ឈរបែបនេះ គឺដើម្បីរកសាច់ស៊ីតែប៉ុណ្ណោះ ។ ឥឡូវនេះខ្ញុំ	

<table>
<tr><td></td><td>មិនចង់រស់នៅជាមួយនឹងលោកទៀតទេ ។ ខ្ញុំនឹងវិលត្រឡប់ទៅរស់នៅជាមួយឪពុកម្ដាយរបស់ខ្ញុំនៅលើផែនដីនោះវិញ" ។ ឮដូច្នេះលោកខែដាក់បណ្ដាសាទៅសត្វមៀមនោះ ៖ "អូនឯងទៅចុះ! អូនឯងវិលត្រឡប់ទៅពិភពផែនដីវិញដើម្បីរកប្ដីថ្មី ។ ប្ដីថ្មីនោះមិនស្មើនឹងខ្ញុំទេ! អូនឯងច្បាស់ជានឹកសោកស្ដាយចំពោះខ្ញុំជាមិនខាន" ។
ក្រោយមកសត្វមៀមក៏ហើរពីលើមេឃចុះមកពិភពផែនដី ។ រស់នៅជាមួយឪពុកម្ដាយបានពីរខែ សត្វមៀមនោះក៏យកប្ដីថ្មី ។ ប្ដីរបស់វានោះឈ្មោះថាអាចេក ។ វារួមរស់ជាមួយប្ដីរបស់វានោះអស់រយៈពេលពីរឆ្នាំ ។ ក្រោយមកប្ដីរបស់វាក៏ស្លាប់ទៅបាត់ ។ យើងដឹងហើយថាដើមចេកដុះមិនរស់យូរទេ ។ វាដុះពីតូចរហូតដល់ធំ ។ វាបញ្ចេញផលផ្លែ រួចវាក៏ងាប់បាត់ទៅហើយរលាយទាំងដើមទាំងគល់" ។ នៅពេលសត្វមៀមបានឃើញប្ដីរបស់វាងាប់ដូច្នេះ វាក៏ស្រែកយំសោកស្ដាយចំពោះប្ដីរបស់វាជារៀងរាល់ថ្ងៃ ។ ការស្រែកយំសោកស្ដាយរបស់វាក៏ឮទៅដល់លោកខែជាប្ដីដើម ។ លោកខែក៏ចុះមកផែនដី ដើម្បីមើលប្រពន្ធរបស់ខ្លួនហើយសួរ ៖ "ហេតុអ្វីបានអូនឯងយំដូច្នេះ?" ប្រពន្ធជាសត្វមៀមឆ្លើយឡើង ៖ "ខ្ញុំយំនឹកប្ដីរបស់ខ្ញុំ" ។លោកខែក៏និយាយបន្ទោសទៅវិញ ៖ "ហ្នឹងហើយខ្ញុំថាអោយអូនឯងពីមុននោះកុំចាកចោលបងអី តែអូនមិនស្ដាប់បងសោះ ។ បើសិនជាអូននៅជាមួយបងជាប្ដីប្រពន្ធនឹងគ្នារហូតនោះ ប្ដីរបស់អូនមិនបាត់បង់យ៉ាងដូច្នេះទេ ។ ខ្ញុំបានប្រាប់ហើយថា បើសិនជាអូនយកប្ដីផ្សេងពីបង អ្នកនោះមិនអាចរស់យូរបានទេ មានតែបងម្នាក់គត់ដែលមានជីវិតអមតៈ រស់រហូតមិនចេះស្លាប់" ។ ឮដូច្នោះសត្វមៀមក៏សុំអង្វរទៅលោកខែវិញ ៖ "បើអីចឹង ខ្ញុំសូមត្រឡប់ទៅវិញធ្វើជាប្រពន្ធនឹងលោកម្ដងទៀតផងបានទេ?" លោកខែឆ្លើយ ៖ "គ្មានច្បាប់ទម្លាប់យ៉ាងនោះទេ ។ អូនឯងបានលែងលះជាមួយនឹងបងរួចទៅហើយ ចាប់ពីថ្ងៃនេះទៅអូនដើរផ្លូវរបស់អូន បងដើរផ្លូវរបស់បង" ។ សត្វមៀមឮពាក្យលោកខែនិយាយដូច្នោះក៏ចាកចេញទៅបាត់ ។ វាស្រក់ទឹកភ្នែកស្រែកយំនឹកស្រណោះសោកស្ដាយយ៉ាងខ្លាំង ។ ប្ដីចុងក៏ស្លាប់ ឯប្ដីដើមក៏ចាកចេញទៅបាត់ទៀត ។ រស់នៅមិនដឹងពឹងពាក់នរណាទេ សុខចិត្តរស់នៅតែម្នាក់ឯងរហូតមកទល់សព្វថ្ងៃនេះ ។ នៅពេលលោកខែពេញបូណ៌មីសត្វមៀមតែងតែស្រែកយំនឹករលឹកចំពោះប្ដីរបស់វាជានិច្ច ពីព្រោះវាដឹងថា ប្ដីរបស់វាមិនមែនជាបិសាចព្រៃទេ គឺជាប្ដីដ៏ល្អបំផុតមិនចេះស្លាប់មិនចេះរលាយឡើយ ៕
<u>សំនួរ</u>
-តើសត្វមៀមរៀបការជាមួយនរណា?
-ហេតុអ្វីបានជាសត្វមៀមលែងលះជាមួយនឹងលោកខែ?
-តើប្ដីថ្មីរបស់សត្វមៀមដែលយកនៅលើផែនដីរស់បានយូរដែរឬទេ?</td></tr>
<tr><td>៨០</td><td>ចូរអោយសិស្សសរសេរតែងរំលឹកមេរៀនមុន អំពីជំងឺគ្រុនចាញ់ និងការរៀបការ</td></tr>
<tr><td>៨១</td><td>រៀនអាន</td></tr>
<tr><td></td><td><u>ក្មេងប្រុសឈ្មោះង៉ែដើររកជ័រក្នុងព្រៃ</u></td></tr>
</table>

កាលពីយូរមកហើយមានក្មេងប្រុសម្នាក់ឈ្មោះង្ហៃ រស់នៅក្នុងភូមិជាមួយនឹងពូ ។ ក្រោយមកពូនោះទៅរស់នៅជាមួយនិងប្រពន្ធ ។ ឯក្មេងឈ្មោះង្ហៃនោះក៏រស់នៅជាមួយម្ដាយនិងយាយ ។ លុះក្រោយមកប្រជាជននៅក្នុងភូមិនោះបបួលគ្នាទៅរកជ័រដែលជ្រុះនៅក្នុងព្រៃ ដើម្បីយកទៅលក់អោយឈ្មួញទីផ្សារ ។ ពួកគេរកជ័រនៅរដូវប្រាំងក្រោយពីគេដុតស្មៅឆេះអស់ ។ ក្មេងឈ្មោះង្ហៃនោះក៏សុំពូ ៖ "ពូអើយ! ខ្ញុំសុំទៅតាមពូរកជ័រដែរ តើបានទេ?" ពូក្មេងនោះឆ្លើយ ៖ "បាន" ។

ក្មេងនោះក៏ទៅតាមពូ ។ ដល់ពាក់កណ្ដាលផ្លូវមានអ្នកខ្លះស្ដីអោយក្មេងឈ្មោះង្ហៃនោះ ៖ "តើឯងមកធ្វើអី ប្រយ័ត្នបាត់ខ្លួននៅកណ្ដាលព្រៃជ្រៅ" ឯងគួរតែត្រឡប់ទៅវិញទៅ កុំតាមពួកអញទៀតក្រែងខ្លាខាំខ្លាស៊ី" ។ ក្មេងនោះមិនចង់ត្រឡប់មកវិញសោះ ។ ពួកគេក៏វាយដំច្រំធាក់ក្មេងនោះហើយនិយាយ ៖ "ឯងដើររកជ័រតែម្នាក់ឯងទៅ" ។ ចំណែកពូមិនជួយក្មេងនោះសោះ ហើយក៏តាមពួកគេនោះដែរ ។ គេទុកចោលក្មេងនោះនៅពីក្រោយ ហើយរកជ័រតែម្នាក់ឯង ។ វាខំរកជ័រពីក្រោយគេមិនបានសោះ ។ រីឯពួកគេនោះវិញបានជ័រច្រើនណាស់ រួចក៏នាំគ្នាត្រឡប់មកផ្ទះវិញដាំបាយសម្ល ។ ឯក្មេងនោះនៅក្រោយគេគិតតែពីរកជ័រនោះដោយម្នាក់ឯង ស្រាប់តែគាត់បានឃើញកុយរមាសសៀតជាប់នឹងវល្លិ៍ផ្ដៅនិងដើមឫស្សី ក៏រើសយកមកដាក់ក្នុងកាផារបស់ខ្លួន ។ វាមិនដឹងថាជាកុយរមាសទេ ។

ដល់ព្រឹកឡើង ពួកគេក៏បបួលគ្នាទៅលក់ជ័រនោះអោយទៅឈ្មួញទីផ្សារ ។ ក្មេងនោះសុំទៅតាមគេដែរ ។ គេស្ដីអោយក្មេងនោះទៀត ៖ "ឯងតាមមកធ្វើអី! តើមានរបស់អីខ្លះយកទៅលក់? ឯងតាមយើងគឺដើម្បីអោយពួកយើងចែកប្រាក់អោយឯងឬ? តែពួកយើងមិនចែកប្រាក់អោយឯងទេ" ។ ក្មេងឈ្មោះង្ហៃនោះមិនចង់ត្រឡប់មកវិញសោះ ហើយខំទៅតាមគេរហូតដល់ទីផ្សារ ។ ទៅដល់ទីផ្សារហើយ ពួកគេក៏លក់ជ័រនោះអោយឈ្មួញគ្រប់ៗគ្នា ។ រីឯក្មេងនោះនៅក្រោយគេដើរតែលតោលតែម្នាក់ឯង ។ ឃើញក្មេងដើរម្នាក់ឯងដូចនោះឈ្មួញក៏សួរ ៖ "តើប្អូនមានរបស់អ្វីយកមកលក់?" ក្មេងឈ្មោះង្ហៃឆ្លើយ ៖ "ខ្ញុំមិនមានរបស់លក់ទេ" ។ ឈ្មួញដើរទៅអើតមើលក្នុងកាផារបស់ក្មេងនោះក៏ឃើញកុយរមាស ។ បានឃើញកុយរមាស ហើយឈ្មួញនិយាយទាំងអរក្នុងចិត្ត ៖ "អូ៎! កុយរមាស!" ដូច្នេះគាត់ក៏ដឹកដៃក្មេងនោះចូលក្នុងផ្ទះអោយហូបបាយ អោយប្រាក់ ក្រណាត់ ខោអាវ យ៉ាងច្រើន ។ ចំណែកពួកអ្នកដែលស្អប់ខ្ពើមក្មេងនោះ ឈរមើលលោភចង់បានប្រាក់គេបាននិយាយគ្នា ៖ "យី! តើប្អូនង្ហៃនេះ ធ្វើយ៉ាងម៉េចបានប្រាក់ច្រើនម្ល៉េះហ្ន៎?"

ក្រោយមកឈ្មួញបានអោយគេជូនក្មេងនោះវិលត្រឡប់មកផ្ទះវិញ ជាមួយនឹងរទេះគោក្របីពីរបីគ្រឿង ។ ក្រោយមកវាក្លាយជាអ្នកមានទ្រព្យសម្បត្តិច្រើន ។ មនុស្សក្នុងភូមិដែលអត់ឃ្លានគ្មានស្រូវក៏ទៅសុំស្រូវក្មេងនោះទាំងអស់គ្នាទៅ ៕

<u>សំនួរ</u>

១-ក្មេងប្រុសឈ្មោះង្ហៃសុំតាមគេរកជ័រ តើគេអោយគាត់ទៅជាមួយដែរឬទេ?

	២-ក្មេងប្រុសឈ្មោះង៉ែកំពុងរកជ័រក្នុងព្រៃ តើគាត់បានឃើញរបស់អ្វីខ្លះជាសំខាន់? ៣-ក្មេងប្រុសឈ្មោះង៉ែរើសបានកុយរមាសហើយ តើគាត់ក្លាយទៅជាយ៉ាងណា?
៨៥	**មេរៀនទី៩១**
	បង្រៀនជើងព្យញ្ជនៈ ្ព
	ពាក្យគន្លឹះ: **ទោច ផ្ទះ**
៨៦	រៀនអាន
	<u>របៀបធ្វើផ្ទះបុរាណនិងសម័យរបស់ជនជាតិព្នង</u> ការរស់នៅជាមួយនឹងផ្ទះសំបែងកាលពីសម័យបុរាណ ប្រៀបធៀបទៅនឹងសម័យឥឡូវនេះខុសប្លែកពីគ្នា ។ ជីដូនជីតារបស់យើងពីបុរាណតែងតែធ្វើផ្ទះពីរដូចគ្នា គឺមួយនៅភូមិមួយទៀតនៅឯចំការ ។ ប៉ុន្តែប្រៀបធៀបនឹងផ្ទះជនជាតិព្នងបច្ចុប្បន្ននេះ ខុសប្លែកពីបុរាណបន្តិច តាមសម័យរីកចំរើន ។ ពីបុរាណជនជាតិព្នងធ្វើផ្ទះរបៀបនេះ ឧទាហរណ៍ទទឹងបួនម៉ែត្រ បណ្តោយប្រាំមួយម៉ែត្រ ។ គេកាប់ដើមឈើមូលធ្វើជាសសរជើងរៀងដប់ប្រាំមួយដើម សសរកន្លោងកណ្តាលបួនដើម សំរាប់ធ្វើជង្រុកដាក់ស្រូវ ។ គេមិនកាប់ដើមឈើណាដែលឆាប់ពុកផុយនោះទេ គឺរកដើមឈើណាដែលមានខ្លឹម ហើយរឹងមាំជានិច្ច ។ សសរជើងរៀងនឹងសសរកន្លោងកណ្តាល មានប្រវែងខុសគ្នា គឺសសរកន្លោងកណ្តាលវែងជាងសសរជើងរៀង ។ ឧទាហរណ៍ មានមនុស្សម្នាក់ក្នុងភូមិ ចង់សង់ផ្ទះមួយសំរាប់ស្នាក់នៅ ។ ដូច្នេះគាត់ត្រូវទៅរកកាប់ដើមឈើ ដើមឫស្សី និងខ្សែសំរាប់ចងទុកជាស្រេច ។ ក្រោយមកគាត់ក៏ហៅគ្នីគ្នាក្នុងភូមិជាមួយគ្នាអោយមកជួយសាងសង់ឡើង ។ គាត់ហៅតែមនុស្សប្រុសៗប៉ុណ្ណោះអោយមកជួយសាងសង់ផ្ទះរបស់គាត់ ។ នៅពេលពួកគេមកជួបជុំគ្នាអស់ហើយ គាត់ក៏ចែកការងារដែលត្រូវធ្វើម្នាក់ៗ ៖ ពីរនាក់ធ្វើខាងកាប់លាក់សសរ និងផ្ទៃងផ្ទាន ម្នាក់ទៀតខាងពុះជ្រៀកតម្រឹមឫស្សី និងធ្វើខ្នួចចងស្បូវ ។ មនុស្សខ្លះទៀតនាំគ្នាជីកដីដាក់សសរជើងរៀងដាក់សសរកន្លោងកណ្តាលនិងត្បាញស្បូវ ជាដើម ។ ចំណែកឯប្រពន្ធម្ចាស់ផ្ទះវិញ នាងជាអ្នកធ្វើម្ហូបអាហារសំរាប់ភ្ញៀវទទួលទានថ្ងៃត្រង់ ។ ពួកគេនាំគ្នាកសាងសង់ផ្ទះនោះរួចជាស្រេច រយៈពេលបីថ្ងៃទៅបួនថ្ងៃ ។ បើយើងសំលឹងមើលទៅដំបូលផ្ទះនោះ យើងឃើញពីលើប្រក់ស្បូវជុំវិញតួផ្ទះគ្រប់បាំងដោយជញ្ជាំងឫស្សី ។ មានទ្វារធំសំរាប់ចេញចូលពីរ ប៉ុន្តែអត់មានបង្អួចទេ ។ មានជង្រុកដាក់ស្រូវពីលើចង្រានមួយ មានគ្រែគេងអមសងខាង ផ្លូវដើរចេញចូលមួយនៅកណ្តាល ។ នៅលើក្បាលដំនេកគ្រែទាំងនោះ គាត់រៀបចំតាក់តែងដាក់ពាងស្រា ព្យួរឃ្មោះ គង ជាដើម ។ ផ្ទះនោះមិនតូចមិនធំ សមល្មមសំរាប់មួយគ្រួសារស្នាក់នៅបាន ។ ពេលរដូវក្តៅយើងនៅក្នុងផ្ទះនោះគឺផាសុកភាពល្អណាស់ ។ ចំណែកនៅពេលរដូវវស្សាវិញគឺត្រជាក់ ។ ចំណែកផ្ទះជនជាតិព្នងក្នុងសម័យរីកចំរើនបច្ចុប្បន្ននេះ គឺខុសប្លែកពីសម័យបុរាណ

	ដោយសារតែទៅតាមសម័យរីកចំរើនក្នុងសង្គមបន្តិចម្តងៗ ។ ឧទាហរណ៍ដូចជា ៖ ធ្វើខ្ពស់មួយខ្នង គេសាងសង់អំពីឈើ ប្រក់សង្កសី ផ្ទៀង ផ្ទាន រនូតនិងក្តារជញ្ជាំងសុទ្ធតែឈើចេញពីរោងចក្រទាំងអស់ ។ នេះគឺដោយសារតែបច្ចុប្បន្ននេះគេមានម៉ាស៊ីនអារឈើ ម៉ាស៊ីនឈូសឈើនិងដែកដាប់ឈើ ។ នេះក៏ដោយសារតែគេបានរៀនសូត្រពីអ្នកបច្ចេកទេស ។ ប៉ុន្តែមានអ្នកខ្លះក្រីក្រតោកយ៉ាក ខ្លះគ្មានគោក្របីគ្មានលុយកាក់សំរាប់ទិញឈើធ្វើផ្ទះទេ ។ ដូច្នេះគេក៏សាងសង់ផ្ទះអំពីឈើមូល របៀបបុរាណតូចៗផងដែរ ។ ជនជាតិព្នងក្នុងបច្ចុប្បន្ននេះធ្វើផ្ទះហើយ គេមិនមានតំណមដូចពីបុរាណទេ ។ គេអាចធ្វើរបងព័ទ្ធជុំវិញផ្ទះ ដើម្បីការពារគោក្របីកុំអោយវាជុះអាចម៍ពាសពេញផ្ទះរបស់ពួកគេ ។ ប៉ុន្តែសម័យបុរាណវិញ គេមិនអាចធ្វើរបងដូច្នោះបានទេគឺតំណម ។ បើសិនជាយើងចង់ធ្វើរបស់ព័ទ្ធជុំវិញផ្ទះរបស់យើង កាត់ព្រំប្រទល់របស់អ្នកជិតខាង មានន័យថាយើងចែកវណ្ណៈនឹងអ្នកជិតខាង ។ នៅពេលអ្នកជិតខាងមានជំងឺឈឺ គឺគេនឹងចោទប្រកាន់យើង ថាមកពីយើងធ្វើរបងទើបធ្វើអោយគេកើតមានបញ្ហាបែបនេះ ។ ជំនឿនេះពេលខ្លះធ្វើអោយជនជាតិព្នងជឿជាក់ដែរ ។ ឧទាហរណ៍ មានអ្នកបរបាញ់ម្នាក់ ដើរទៅក្នុងព្រៃដើម្បីរកសត្វ ។ នៅពេលគាត់បាញ់សត្វបានហើយ គាត់មិនហ៊ានដើររំលងជើងសត្វដែលងាប់នោះទេ ។ បើសិនជាគាត់ហ៊ានរំលងខុសពីជំនឿ ថ្ងៃក្រោយគាត់បរបាញ់សត្វលែងបានទៀតហើយ ។ នេះគឺជាជំនឿមួយដែរសំរាប់ជនជាតិព្នង ។ ការរស់នៅនិងទំនៀមទំលាប់របស់ជនជាតិព្នង ពីបុរាណប្រៀបធៀបទៅនឹងបច្ចុប្បន្ននេះ មិនសូវខុសគ្នាប៉ុន្មានទេ ។ បើសិនជាមិនបានទទួលការរៀនសូត្រពីអ្នកដទៃជនជាតិព្នងយើងមិនអាចលះបង់ចោលទំនៀមទំលាប់អាក្រក់ និងការរស់នៅអោយរីកចំរើនបានឡើយ ៕ **<u>សំនួរ</u>** -តើផ្ទះជនជាតិព្នងពីបុរាណនិងសម័យ មានលក្ខណៈខុសគ្នាដែរឬទេ? ពីព្រោះអ្វី? -តើផ្ទះជនជាតិព្នងពីបុរាណគេធ្វើយ៉ាងដូចម្តេច? -បច្ចុប្បន្ននេះ តើពួកគេធ្វើផ្ទះដូចម្តេចដែរ? -ហេតុអ្វីបានជាជនជាតិព្នងពីបុរាណមិនធ្វើរបងព័ទ្ធជុំវិញផ្ទះ?	
៩០	រៀនសរសេរ	-នើនកំពុងតែកាន់សាច់ជ្រូកព្រៃមួយដុំនៅនឹងដៃ ។ -ម្តាយរបស់នើនរត់ទៅរើសផ្លែពោនដែលជ្រុះនៅលើដី ។ -នើនស្ពាយសាច់ជ្រូកព្រៃត្រឡប់មកផ្ទះវិញ ។
៩១	ចូរជ្រើសរើសជើងព្យញ្ជនៈ "" សរសេរប្រកបអោយបានបីពាក្យ ៖ ជ្រើសរើសបីពាក្យដែលបានសរសេរខាងលើ ហើយតែងអោយបានបីប្រយោគខាងក្រោម ៖	
៩៣	**មេរៀនទី៩២**	
	បង្រៀនព្យញ្ជនៈ	ផ

	ពាក្យគន្លឹះ	**អង្ករ ភួយ**
៩៤	រៀនអាន	
	<u>**បងនើននិងបងតាយនាំគ្នាទៅផ្សារ**</u> ថ្ងៃនេះបងនើនបបួលបងតាយដើរទៅផ្សារ ដើម្បីរកទិញភួយនិងអង្ករ ។ បងនើនបបួលបងតាយទៅទិញភួយនិងអង្ករដូចនេះ ព្រោះតែភួយរបស់បងនើនចាស់រហែកអស់ហើយ អង្ករដាំបាយក៏អស់ដែរ ។ បងនើននិយាយទៅបងតាយ ៖ "បងតាយអើយ! ថ្ងៃនេះយើងនាំគ្នាដើរទៅផ្សារ តើបានទេ?" បងតាយសួរ ៖ "តើយើងទៅផ្សារធ្វើអ្វីទៅប្អូន?" នើននិយាយ ៖,"យើងទៅផ្សារដើម្បីរកទិញភួយព្រមទាំងអង្ករណាបង! ព្រោះអីអង្កររបស់ខ្ញុំជិតអស់រលីងទៅហើយ" ។ បន្ទាប់មកពួកគេនាំគ្នាធ្វើដំណើរទៅដល់ផ្សារ ។ ពួកគេនាំគ្នាដើររកភួយនិងអង្ករ ។ បងនើនទិញភួយបានពីរ អង្កររមួយបាវ ។ ចំណែកបងតាយវិញ ទិញភួយបានពីរអង្ករបានពីរបាវដែរ ។ ដល់ខែរងារ បងនើនយកភួយដែលទើបតែទិញថ្មីនោះ មកដណ្តប់យ៉ាងកក់ក្តៅ ។ ដណ្តប់បានមួយអាទិត្យ បងនើនក៏យកភួយទៅបោកគក់អោយស្អាត ។ គាត់ថែរក្សាបែបនេះដើម្បីការពារកុំអោយវាឆាប់ចាស់ និងរហែកនិងប្រើប្រាស់បានយូរ ៕	
៩៥	រៀនសរសេរ	-ថ្ងៃនេះបងនើនទៅរកទិញភួយ ។ -បងនើនកំពុងស្ពាយកាផាមួយដែលមានស្រូវ ។
៩៦	ចូរជ្រើសរើសព្យញ្ជនៈ ផ សរសេរប្រកបអោយបានបីពាក្យខាងក្រោមនេះ ៖	
៩៦	ជ្រើសរើសបីពាក្យដែលបានសរសេរខាងលើ ហើយសរសេរតែងអោយបានបួនប្រយោគ ៖	
៩៧	រៀនអាន	
	<u>**ពពួកព្រូន**</u> **ព្រូនមានប្រភេទផ្សេងៗគ្នាគឺអ្វីខ្លះ?** - ព្រូនសំប៉ែត (តេនញ៉ា) - ព្រូនចង្កឹះ ឬ ព្រូនមូល - ព្រូនទំពក់ - អៀន តើពពួកព្រូនបណ្តាលមកពីអ្វី? អ្នកអាចកើតព្រូន ដោយសារបរិភោគសាច់ជ្រូកសាច់គោ ឬ សាច់ត្រីដែលចំអិនមិនបានឆ្អិនល្អត្រឹមត្រូវ ។ ពងព្រូនដែលមាននៅក្នុងលាមកមនុស្ស បានចូលទៅក្នុងម្ហូបអាហារ ដោយសាររុយ ឬដៃកខ្វក់ ។ បើសិនបើក្រុមគ្រួសារទាំងមូលបរិភោគម្ហូបអាហារមិនស្អាត ពួកគេក៏អាចកើតព្រូនទាំងអស់គ្នាបានដែរ ។	

ព្រូនឆ្លងចូលក្នុងខ្លួនតាមបាតជើង ដែលដើរលើដីគ្មានពាក់ស្បែកជើង ។
ក្មេងៗកើតព្រូន ដោយសារញ៉ាំដីដែលមានពងព្រូននោះ ។

រោគសញ្ញារបស់មនុស្សកើតព្រូន ៖

- ពោះប៉ោងហើយឈឺពោះ
- ទំងន់ចុះថយជាលំដាប់
- រមាស់ស្បែក
- ក្អកស្ងួត ។
- ឈឺក្នុងពោះ ហើយចុះរាគ
- រមាស់នៅជុំវិញកន្លែងបត់ជើងធំ
- ស្លេកស្លាំង (ឈាមចុះខ្សោយ) ។

ការព្យាបាលនៅតាមផ្ទះ ៖

ដើម្បីព្យាបាលរោគព្រូនមូលយើងត្រូវ ៖
១ - យកជ័រល្ហុងខ្ចីចំនួន ២ ស្លាបព្រាបាយ
២ - យកទឹកឃ្មុំឬស្ករស ២ ស្លាបព្រាបាយ
៣ - ក្នុងទឹកក្ដៅ ១ ពែង
បញ្ជូកកូនក្មេង (មួយអាទិត្យក្រោយមកត្រូវធ្វើដូចនេះម្ដងទៀត) ។

ប្រសិនបើក្មេងនៅតែមានបញ្ហាដដែលទៀត សូមនាំទៅមណ្ឌលសុខភាព ដើម្បីទទួលការព្យាបាល ។ មានថ្នាំច្រើនយ៉ាងសំរាប់ព្យាបាលពពួកព្រូន ។ សូមប្រើថ្នាំតាមការណែនាំរបស់គ្រូពេទ្យ ។ ជាការល្អ ត្រូវលេបថ្នាំបញ្ចុះព្រូននៅរៀងរាល់ ៤ ឬ ៦ ខែម្ដង ជាពិសេសសំរាប់ក្មេងតូចៗ ។

ពេលដែលត្រូវទៅមន្ទីរពេទ្យ ៖

- ក្អកធ្លាក់ឈាម
- ចុះខ្សោយ និងអស់កំលាំងខ្លាំង
- ឬក៏ហើមពោះយ៉ាងខ្លាំង ។

វិធីការពារកុំអោយកើតព្រូន ៖

ត្រូវសង់ និង ប្រើប្រាស់បង្គន់អនាម័យ ។
ត្រូវលាងដៃអោយស្អាតក្រោយពេលចេញពីបង្គន់ និង មុនពេលរៀបចំម្ហូបអាហារ ឬ

<table>
<tr><td></td><td colspan="2">មុនពេលទទួលទានចំណីអាហារ ។

ត្រូវចំអិនសាច់អោយបានឆ្អិនល្អ ។ កុំញុំាសាច់ឆៅ ឬ សាច់ដែលមិនសូវឆ្អិន ។
ត្រូវគ្របម្ហូបអាហារអោយបានជិតល្អ ដើម្បីការពារកុំអោយរុយរោម ។
ត្រូវញុំាទឹកដែលដាំពុះ ឬ ក៏ទឹកបរិសុទ្ធតែប៉ុណ្ណោះ ។

សូមកុំដាក់ក្មេងតូចៗចោលអោយញុំាដី ។
ត្រូវពាក់ស្បែកជើង កុំដើរជើងទទេ ៕
<u>សំនួរ</u>
ចូរអានសំនួរខាងក្រោមនេះ បន្ទាប់មកសរសេរចំលើយសំនួរទាំងនោះ
១-តើព្រូននៅក្នុងពោះរបស់យើងមានប៉ុន្មានប្រភេទ?
២-ហេតុអ្វីបានជាយើងមានព្រូនក្នុងពោះ?
៣-បើយើងមានព្រូនក្នុងពោះ តើយើងធ្វើយ៉ាងម៉េចទើបដឹងថាមានព្រូន?
៤-តើយើងប្រើថ្នាំអ្វីខ្លះ សំរាប់បញ្ចុះព្រូនក្នុងពោះយើងបាន?
៥-តើយើងគួរតែទៅទិញថ្នាំការពារព្រូននោះនៅទីកន្លែងណាខ្លះ?</td></tr>
<tr><td>១០៣</td><td colspan="2">មេរៀនទី៩៣</td></tr>
<tr><td></td><td>បង្រៀនព្យញ្ជនៈ</td><td>□ឃ្ស</td></tr>
<tr><td></td><td>ពាក្យគន្លឹះ</td><td>អូឃ្ស ជីក</td></tr>
<tr><td>១០៤</td><td colspan="2">រៀនអាន</td></tr>
<tr><td></td><td colspan="2"><u>ដំរីបកស្រាយអំណាចរបស់មនុស្សអោយខ្លាស្ដាប់</u>
ថ្ងៃមួយ មានមនុស្សម្នាក់ចងដំរីមួយក្បាលជាមួយ នឹងដើមឈើក្បែរភូមិរបស់គាត់រស់នៅ ។ ក្រោយមកមានខ្លាមួយក្បាល ដើរមកដល់កន្លែងគាត់ចងដំរីនោះ ហើយសួរទៅដំរី ៖ "ហេតុអីបានលោកខ្លាចមនុស្សខ្លាំងម្ល៉េះ? ខ្លួនរបស់លោកផ្ទាល់ធំជាងពួកគេឆ្ងាយណាស់ មនុស្សគ្រាន់តែជាអ្នកតូចល្អិតមួយប៉ុណ្ណោះ ហេតុអ្វីបានជាគេមានអំណាច ឯលោកគ្មានអំណាចទេវិញ?" ដំរីឆ្លើយតបទៅខ្លាវិញ ៖ "អូ! បើអញ្ចឹង យប់នេះខ្ញុំសូមឃាត់លោកនៅទីនេះជាមួយនឹងខ្ញុំហើយ ដើម្បីអោយលោកឃើញ និងយល់សកម្មភាពរបស់មនុស្សថា តើហេតុអ្វីបានជាពួកគេមានអំណាចលើពួកយើង? ដោយសារតែពួកគេមានប្រាជ្ញា ចេះគិតគូរនិងបច្ចេកទេសច្រើន ដូច្នេះទើបពួកគេមានអំណាចខ្លាំងជាងពួកយើង" ។
ខ្លាក៏នៅជាមួយនឹងដំរី ដើម្បីមើលសកម្មភាពរបស់មនុស្សម្នាក់ ដែលកំពុងតែត្រួតត្រាចំពោះដំរី ។ ក្នុងខណៈពេលពួកវារង់ចាំមើលសកម្មភាពរបស់មនុស្សម្នាក់ ពួកវាអាចឃើញសកម្មភាពអ្វីៗ នៅក្នុងផ្ទះដែលមនុស្សម្នាក់នោះកំពុងតែធ្វើ ។ ចំណែកឯមនុស្សជាអ្នកឃ្វាល</td></tr>
</table>

	ដំរីនោះវិញ គាត់ក្រោកពីគេង យកទឹកលុបមុខ និងសិតសក់ ។ ខ្លាបានឃើញមនុស្សកំពុងធ្វើដូចនោះ វាក៏សួរទៅដំរី ៖ "តើគាត់កំពុងធ្វើអ្វី?" ដំរីឆ្លើយ ៖ "គាត់កំពុងតែលុបមុខនិងសិតសក់" ។ បន្ទាប់មកមនុស្សនោះ ស្ពាយចំកាំបិតធំមួយជាប់នឹងចង្កេះ ។ ខ្លាបានឃើញមនុស្សស្ពាយកាំបិតក៏សួរទៅដំរីទៀត ៖ "តើរបស់អ្វីទៅដែលគាត់ស្ពាយជាប់នឹងចង្កេះនោះ?" ដំរីឆ្លើយពន្យល់ ៖ "អាមួយនោះ គេហៅថាកាំបិត ។ កាំបិតនេះមានសារៈសំខាន់ណាស់ សំរាប់គាត់ ។ គាត់អាចកាប់អ្វីៗបានទាំងអស់ ដូចជាសត្វឬក៏ដើមឈើផ្សេងៗ" ។ បន្ទាប់មកមនុស្សក៏យកជន្លួញចាក់ក្បាលដំរីកាន់នៅនឹងដៃ រួចដើរសំដៅទៅកន្លែងដែលចងដំរី ។ ខ្លាបានឃើញមនុស្សកំពុងតែដើរកាន់ជន្លួញសំដៅមកខ្លួន វារឹតតែភ័យខ្លាចទៅទៀត វាលែងសួរដំរីទៀតហើយ ព្រោះអីវាដឹងថារបស់ដែលមនុស្សកំពុងតែកាន់នៅនឹងដៃនោះហើយជារបស់ដែលវាគួរអោយខ្លាច ។ ដូច្នេះខ្លាប្រុងលួចរត់ចេញពីទីកន្លែងនោះដោយស្ងាត់ៗ ។ ដំរីបានឃើញខ្លាប្រុង នឹងរត់ដូច្នោះ ក៏ឃាត់ខ្លា ៖ "ឯងកុំអាលរត់អីសំឡាញ់ នៅទីនេះ ចាំមើលសិន" ។ តែខ្លាមិនស្តាប់ការហាមឃាត់របស់ដំរីទេ ។ វារត់ចេញពីកន្លែងនោះចូលទៅព្រៃបាត់ រហូតដល់សព្វថ្ងៃនេះ ។ ក្រោយមកមនុស្សក៏មកដល់កន្លែងចងដំរីនោះ ។ គាត់ស្រាយដំរីរបស់គាត់ជិះត្រឡប់មកភូមិរបស់គាត់វិញ ៕ **<u>សំនួរ</u>** ១-តើគេចងដំរីនោះនៅកន្លែងណាខ្លះ? ២-តើខ្លានិយាយទៅកាន់ដំរីយ៉ាងដូម្តេចខ្លះ? ៣-ហេតុអ្វីបានខ្លាខ្លាចមនុស្ស?	
១០៧	រៀនសរសេរ	-ថ្ងៃនេះនើនយកភួយរបស់គាត់ទៅបោក ។ -នើនកំពុងតែអួសអង្ករមួយបាវ ។
១០៨	ចូររជ្រើសរើសស្រះ "ូយ្យ " "ុយ្យ " សរសេរប្រកបអោយបានបីពាក្យខាងក្រោមនេះ ៖	
១០៨	ជ្រើសរើសពីរពាក្យដែលបានសរសេរខាងលើ ហើយតែងអោយបានពីរប្រយោគ ៖	
១០៩	**មេរៀនទី៩៨**	
	បង្រៀនព្យញ្ជនៈ	ថ
	ពាក្យគន្លឹះ:	**ថូ ទាត់**
១១០	រៀនអាន	

	<u>គ្រួសាររបស់ពូថានមានជំងឺអេដស៍</u> ពូថានបានធ្វើទាហានចំនួនពីរឆ្នាំ ។ ក្រោយមកគាត់ត្រឡប់មកភូមិវិញ រួចហើយរៀបការប្រពន្ធ ។ គាត់ស្រឡាញ់ប្រពន្ធគាត់ណាស់ ព្រោះនាងឧស្សាហ៍ធ្វើការងារគ្រប់បែបយ៉ាង ។ អ្នកទាំងពីរមានកំលាំងមាំមួន ។ គេអាចធ្វើចំការបានផលច្រើន ដើម្បីយកទៅលក់នៅផ្សារ ។ គាត់មានកូនពីរនាក់ហើយ ឥឡូវនេះប្រពន្ធរបស់គាត់មានផ្ទៃពោះទៀត ។ ចាប់តាំងពីមានផ្ទៃពោះនេះមក គាត់មិនសូវស្រួលខ្លួន មានរាកច្រើនដង ។ ក្រោយមកបានធូរបន្តិច តែចេះតែមានរាកជាបន្តបន្ទាប់និងចេះតែស្គមទៅៗ នៅពេលយប់មានគ្រុនរងា ។ ពូថានបានទៅទិញថ្នាំច្រើនដង ហើយយកមកអោយប្រពន្ធលេប នៅតែមិនជាដដែល ។ ឥឡូវនេះគាត់មានក្អកផង ។ ពូថានព្រួយចិត្តណាស់ក៏ជូនប្រពន្ធគាត់ទៅពេទ្យខេត្ត ព្រោះគាត់ខ្លាចប្រពន្ធនិងកូននៅក្នុងផ្ទៃស្លាប់ ។ នៅមន្ទីរពេទ្យគ្រូពេទ្យបានពិនិត្យមើលប្រពន្ធនិងជោះឈាមយកទៅមើលផង ។ ក្រោយមកពេទ្យប្រាប់ថាប្រពន្ធរបស់គាត់ថា មានមេរោគអេដស៍ហើយប្រហែលជាកូននៅក្នុងផ្ទៃក៏មានរោគនេះដែរ ។ ប៉ុន្តែគ្រូពេទ្យបានប្រាប់ថា ត្រូវយកឈាមរបស់ប្តីទៅពិនិត្យមើលផង ព្រោះមេរោគនេះវាឆ្លងតាមរយៈការរួមភេទ ។ ពេទ្យបានប្រាប់ទៀតថា មេរោគនេះអាចឆ្លងទៅតាមរយៈទងសួតនិងទឹកដោះ ហើយឆ្លងទៅអ្នកផ្សេងតាមការចាក់ថ្នាំប្រើម្ជុលរួមគ្នា ។ ថ្ងៃក្រោយមកគ្រូពេទ្យបានប្រាប់ថា ពូថានក៏មានមេរោគអេដស៍ដែរ ។ គេចង់ដឹងថាតើគាត់ឆ្លងមេរោគនេះមកពីណា? ពូថានគាត់បានប្រាប់ពេទ្យថា កាលពីគាត់នៅធ្វើទាហានគាត់ធ្លាប់ទៅលេងស្រីពីរបីដងដែរ ។ ពូថានបានសួរទៅគ្រូពេទ្យថា តើត្រូវប្រើថ្នាំអីដើម្បីជាពីជំងឺនេះ? ។ គ្រូពេទ្យបានឆ្លើយវិញថា ជំងឺនេះគ្មានថ្នាំព្យាបាលទេ តែគេអាចព្យាបាលជំងឺផ្សេងៗ ដែលកើតមកពីមេរោគនេះបាន ប៉ុន្តែជំងឺនោះនឹងកើតឡើងមកវិញថ្ងៃក្រោយ ។ ជំងឺនោះមានដូចជា៖ រាក ក្អក រោគសើស្បែក ។ ប៉ុន្តែអ្នកដែលមានមេរោគអេដស៍គឺត្រូវតែស្លាប់នៅពេលខាងមុខ ។ គ្រូពេទ្យអោយថ្នាំលេបទៅប្រពន្ធពូថាន ដើម្បីព្យាបាលជំងឺរាក ក្អក ហើយប្រាប់ទៀតថា ត្រូវតែមានអនាម័យអោយបានល្អ ដើម្បីរស់បានយូរទៅមុខទៀត ដូចជា៖ -ហូបទឹកឆ្អិន បន្លែផ្លែឈើ ត្រូវតែលាងអោយបានស្អាត មិនត្រូវហូបឆៅទេ -ត្រូវលាងដៃអោយបានស្អាតក្រោយចេញពីបង្គន់និងមុនពេលបាយ -ត្រូវហូបម្ហូបអោយបានច្រើនមុខ -ត្រូវដេកក្នុងមុង ។ -នៅពេលមុជទឹកត្រូវដុសលាងសាប៊ូអោយបានស្អាតនិងជូតខ្លួនអោយស្ងួត ។ -ត្រូវបោកខោអាវជារៀងរាល់ថ្ងៃ ។ ដើម្បីកុំអោយអ្នកផ្សេងឆ្លងជំងឺនេះ មិនត្រូវអោយគេប្រើរបស់យើងដូចជាឡាម ម្ជុល កន្ត្រៃកាត់ក្រចក ឬ ទៅលេងស្រីៗ ផ្សេងទៀតទេ ។ ប៉ុន្តែគេអាចថើប ឬ អោបកូនគេបាន ។ប្រពន្ធគាត់បានអរគុណគ្រូពេទ្យដែលបានជួយពន្យល់ណែនាំ ហើយក៏លាត្រឡប់មកផ្ទះវិញទាំងពិបាកចិត្ត ។ ចំណែកពូថានក៏មានការសោកស្តាយយ៉ាងខ្លាំង ដែលខ្លួនបានប្រព្រឹត្តនូវអំពើមិនល្អនេះ ដែលនឹងបណ្តាលអោយគ្រួសាររបស់គាត់ស្លាប់នៅពេលឆាប់ៗ ខាងមុខ ៕

	<u>សំនួរ</u> -ហេតុអ្វីបានពូថាន់មានជំងឺអេដស៍? -តើជំងឺអេដស៍មានថ្នាំព្យាបាលដែរឬទេ? -ដើម្បីរស់អោយបានយូរបន្តិច តើគ្រូពេទ្យណែនាំអោយពូថាន់យ៉ាងដូម្តេចខ្លះ?	
១១៤	រៀនសរសេរ	-នើនទៅដងទឹកនឹងថូ ដើម្បីយកមកលាងជើង ។ -នើនកំពុងតែលាងជើងក្នុងទឹកអូរដែលហូរខ្លាំង ។
១១៥	ចូរជ្រើសរើសព្យញ្ជនៈ " ថ " សរសេរប្រកបអោយបានបីពាក្យខាងក្រោមនេះ ៖	
១១៥	ជ្រើសរើសបីពាក្យដែលបានសរសេរខាងលើ ហើយតែងអោយបានបីប្រយោគ ៖	
១១៧	**មេរៀនទី៥៥**	**មេរៀនរំលឹកឡើងវិញ**
១១៧	លំហាត់តែងសេចក្តី	
១១៧	ចូរអោយសិស្សសរសេរអត្ថបទមួយទាក់ទងនឹងមេរៀន អំពីពពួកព្រូន និងជំងឺអេដស៍	
១១៩	លំហាត់បំពេញប្រយោគ	
	ត្រី ច្រើន បាន ឈឺក្បាល ជា ពូ គ្រុនញាក់ ខ្លួន ថ្នាំ គ្រូពេទ្យ ផ្ទះ ចូរជ្រើសរើសពាក្យខាងលើនេះ យកទៅសរសេរបំពេញក្នុងប្រយោគខាងក្រោមនេះ ៖	
	ពីរនាក់ពូនិងក្មួយវិលត្រឡប់ពីព្រៃមកផ្ទះវិញ ។ មកដល់ផ្ទះម្តាយរបស់នើនសួរនើន ៖ "តើនើនឯងបានត្រីប៉ុន្មានទៅ?" នើនបានឆ្លើយ ៖ "បាទ! ម៉ាក់ បានតែន្តិចបន្តួចទេពូបានច្រើនណាស់ម៉ាក់" ។ ក្រោយមកនើនហុចត្រីនោះអោយទៅម្តាយរបស់គាត់ ។ ម្តាយរបស់គាត់យកត្រីនោះធ្វើម្ហូបពិសារ ។ ចំណែកពូរបស់នើនក៏អោយត្រីខ្លះទៅម្តាយរបស់នើនដែរ ។ រួចគាត់ក៏ដើរទៅផ្ទះរបស់គាត់វិញ ។ បន្តិចក្រោយមកនើនក៏ចាប់ផ្តើមគ្រុនញាក់ និងឈឺក្បាលទៀតផង ដោយសារគាត់បានលេងទឹកយូរពេក ។ ដូច្នេះគាត់ក៏ទៅគេងក្នុងបន្ទប់ ។ នៅពេលម្តាយធ្វើម្ហូបត្រីនោះឆ្អិនហើយ ឪពុកម្តាយស្រែកហៅនើនមកពិសាបាយ តែនើនបានឆ្លើយទៅ វិញ ៖ "ខ្ញុំមិនអាចក្រោកបានទេ ខ្ញុំឈឺក្បាលខ្លាំងណាស់" ។ ឮកូនស្រែកប្រាប់ដូចនោះម្តាយក៏ទៅសួរកូនក្នុងបន្ទប់ ៖ "តើកូនឯងឈឺក្បាលខ្លាំងណាស់មែនទេ?" នើនឆ្លើយ ៖ "បាទ! ម៉ាក់ ខ្ញុំឈឺណាស់ គ្រុនញាក់ ឈឺក្បាល និងផ្តាសាយទៀតផង" ។ ក្រោយមកម្តាយរបស់គាត់ទៅជួបលោកគ្រូពេទ្យនៅក្នុងភូមិ ដើម្បីអោយគ្រូពេទ្យនោះពិនិត្យមើលជំងឺកូនរបស់គាត់ ។ គ្រូពេទ្យក៏ពិនិត្យមើលហើយ នឹងស្ទាបមើលខ្លួនប្រាណរបស់នើនហើយសួរ ៖ "ប្អូននើន តើឯងឈឺយ៉ាងម៉េច?" នើនឆ្លើយ ៖ "បាទ! លោកគ្រូពេទ្យ ខ្ញុំគ្រុនញាក់និងផ្តាសាយធំ" ។ បន្ទាប់មកគ្រូពេទ្យអោយថ្នាំសំរាប់លេបហើយនិយាយ ៖ "ឥឡូវនេះ សូមឯងលេបថ្នាំដែលខ្ញុំបានអោយនេះសិន បើមិនជាសះស្បើយទេ សូមអ្នកស្រីមកជួបខ្ញុំម្តងទៀត" ។ ក្រោយមកនើនក៏លេបថ្នាំ ដែលលោកគ្រូពេទ្យបានអោយនោះរហូតដល់អស់ គាត់ក៏បានជាជំងឺនោះ ៕	

១២១	**មេរៀនទី៩៦**
	បង្រៀនព្យញ្ជនៈ: អ្យ
	ពាក្យគន្លឹះ: មាន់
១២២	រៀនអាន

អំពីជំងឺមាន់

ការចិញ្ចឹមមាន់មានសារៈសំខាន់ណាស់ សំរាប់ប្រជាជននៅតាមជនបទ ។ មាន់អាចរកចំណីដោយខ្លួនឯងបាន ។ សត្វមាន់ងាយស្រួលក្នុងការចិញ្ចឹមព្រោះវា មិនសូវត្រូវការថែរក្សាខ្លាំងដូចសត្វផ្សេងៗទេ ។ យើងអាចចិញ្ចឹមមាន់សំរាប់យកសាច់ ឬ សំរាប់លក់ទៅទីផ្សារ ។ មាន់ជាសត្វ ដែលផ្តល់ផលច្រើនដល់ប្រជាកសិករ ប៉ុន្តែនៅរដូវផ្សេងៗ សត្វមាន់ច្រើនទទួលនូវការឆ្លងជំងឺ ហើយអាចងាប់ជាញឹកញាប់ ។

ជួនកាលនៅរដូវខ្លះ នៅពេលដែលមានមេរោគចូលក្នុងភូមិ សត្វមាន់ជិតមួយរយភាគរយទទួលនូវការឆ្លងជំងឺ ហើយងាប់យ៉ាងច្រើន ។ យើងរៀបចំឯកសារនេះដើម្បីជួយកាត់បន្ថយនូវការងាប់របស់សត្វមាន់និងជួយទប់ស្កាត់នូវការឆ្លងជំងឺ ផ្សេងៗ ។

<u>ជំងឺដែលតែងតែកើតលើសត្វមាន់នៅស្រុកខ្មែរ</u>

ជំងឺដែលសំខាន់ជាងគេនៅស្រុកខ្មែរ ដែលតែងតែកើតលើសត្វមាន់គឺជាជំងឺអាសន្នរោគនិងជំងឺ «ដង្កោរែក» ឬ «ញ៉ីវកាស» ។ ជំងឺទាំងពីរនេះ ងាយឆ្លងពីសត្វមួយទៅសត្វមួយ និងធ្វើអោយមាន់ងាប់ភ្លាម ។

<u>ជំងឺអុតមាន់</u>

ជំងឺមួយទៀត គឺជំងឺអុតមាន់ ដែលមិនសូវធ្វើអោយមាន់ងាប់ ប៉ុន្តែជំងឺនេះងាយឆ្លងនិងធ្វើអោយសត្វមានសុខភាពខ្សោយ ។

<u>ការប្រើថ្នាំការពារ</u>

ដើម្បីកាត់បន្ថយនូវការងាប់របស់សត្វមាន់យើងត្រូវចាក់ថ្នាំការពារ មុនពេលដែលវាមិនទាន់ទទួលនូវការឆ្លងជំងឺ ពីព្រោះសត្វមាន់នៅពេលដែលវាកើតជំងឺហើយ យើងមិនអាចព្យាបាលវាជាទេ ហើយបើព្យាបាលបានប្រហែលជាតិចតួចប៉ុណ្ណោះ ។

បើសិនជាយើងយល់ និងប្រើថ្នាំការពារតាមកម្មវិធីនេះ យើងអាចកាត់បន្ថយនូវការងាប់របស់សត្វមាន់ហើយ ជំងឺក៏មិនអាចកើត ឬ ឆ្លងទៅសត្វរបស់យើងបានទេ ។

<u>ការចាក់វ៉ាក់សាំងលើកូនមាន់ការពារជំងឺទាំង៣</u>

ដើម្បីការពារជំងឺ «ញ៉ីវកាស» ឬ «ដង្កោរែក»

នៅពេលដែលមាន់ទើបតែញាស់បាន ៣ ថ្ងៃ យើងប្រើវ៉ាក់សាំង«ញ៉ីវកាស ធ»បន្តក់ក្នុងភ្នែកសងខាងដោយម្ខាងមួយដំណក់ ។

<u>ដើម្បីការពារជំងឺអុតមាន់</u>

នៅពេលដែលមាន់មានអាយុ ១៥ ថ្ងៃ យើងប្រើវ៉ាក់សាំងអុតមាន់ចាក់ស្លាបវាដោយប្រើម្ជុលពិសេស ។

ដើម្បីការពារជំងឺ«ញ៉ូវកាស» ឬ «ដង្កោវែក»

នៅពេលដែលមាន់មានអាយុ ៣០ ថ្ងៃយើងប្រើវ៉ាក់សាំង«ញ៉ូវកាសំ» ។ សំរាប់មាន់មួយក្បាលយើងចាក់ថ្នាំ ចំនួន 0,05 សេសេ ដោយចាក់សាច់ដុំទ្រូងរបស់វា ។

<u>ដើម្បីការពារជំងឺអាសន្នរោគ</u>

នៅពេលដែលមាន់មានអាយុ៦០ថ្ងៃ យើងប្រើវ៉ាក់សាំងអាសន្នរោគ ។ សំរាប់មួយក្បាលយើងចាក់ ១ សេសេ ដោយចាក់សាច់ដុំទ្រូងរបស់វា ។ ដើម្បីការពាររបួត យើងចាក់ថ្នាំដូចមាន់ធំដែរ ។

<u>ចូរចាក់ការពាររបួតដូចមាន់ធំដែរ</u>

ដើម្បីការពារជំងឺ «ញ៉ូវកាស» យើងចាក់រាល់ ៤ ខែម្តង ។ ដើម្បីការពារជំងឺអាសន្នរោគយើងចាក់រាល់ ៦ ខែម្តង ។

<u>ការចាក់វ៉ាក់សាំងលើមាន់ធំ</u>

ចំពោះមាន់ធំ យើងប្រើវ៉ាក់សាំង «ញ៉ូវកាសM» ដោយចាក់ក្នុងសាច់ដុំទ្រូងរបស់វា ចំនួន 0,05សេសេ ។ យើងចាក់ វ៉ាក់សាំង អាសន្នរោគ ១ សេសេ ដោយចាក់នៅក្នុងសាច់ដុំទ្រូងម្ខាងទៀត ។ ហាមចាក់កន្លែងដដែល ។

មួយខែក្រោយមកយើងចាក់វ៉ាក់សាំង «ញ៉ូវកាសM» 0,05 សេសេ ដោយចាក់នៅត្រង់សាច់ដុំទ្រូងម្តងទៀតជាការរំលឹក ។ យើងប្រើវ៉ាក់សាំង អុតមាន់ ចាក់ក្នុងសាច់ដុំស្លាបរបស់វា ដោយប្រើម្ជុលពិសេស ។

<u>ចូរចាក់ការពាររបួត</u>

សំរាប់ថ្នាំការពារ ឬ វ៉ាក់សាំងការពារជំងឺ «ញ៉ូវកាស» និងអាសន្នរោគនេះ យើងគួរចាក់ក្នុងរយៈពេល ៤ ខែម្តង ពីព្រោះថ្នាំអាចការពារតែ ៤ ខែប៉ុណ្ណោះ ។ ការចាក់ថ្នាំអាសន្នរោគ គឺ ៦ ខែម្តង ។

<u>ថ្នាំការពារ</u>

ថ្នាំការពារទាំងបួនមុខនេះយើងអាចទិញនៅមន្ទីរកសិកម្ម ដែលមានតំលៃដូចខាងក្រោម ៖

ថ្នាំការពារជំងឺ «ញ៉ូវកាស F» 3,500៛ ក្នុងមួយដបការពារមាន់ 100 ក្បាល ។

ថ្នាំការពារជំងឺ «ញ៉ូវកាស M» 4,000៛ ក្នុងមួយដបការពារមាន់ 100 ក្បាល ។

ថ្នាំការពារជំងឺអាសន្នរោគមាន់ 5,000៛ ក្នុងមួយដបអាចចាក់មាន់បានចំនួន 100ក្បាល ។

ថ្នាំការពារជំងឺអុតមាន់ 4,000៛ ក្នុងមួយដបអាចចាក់មាន់បានចំនួន 100 ក្បាល ។

ថ្នាំការពារខ្លះយើងត្រូវការដាក់វានៅក្នុងធុងទឹកកករបួត ។ មន្ទីរអាចផ្តល់ទឹកកកអោយអ្នកបាន ។ ប៉ុន្តែត្រូវមានធុងទឹកកកខ្លួនឯង ។ ចូរយើងបបួលគ្នាពីពីរគ្រួសារ ទៅបីគ្រួសារ

	ដើម្បីចូលគ្នាទិញថ្នាំនេះ ៕ **<u>សំនួរ</u>** ១-ក្នុងប្រទេសកម្ពុជារបស់យើងនេះ តើជំងឺអ្វីខ្លះដែលឆាប់ប៉ះពាល់ដល់សត្វមាន់? ២-តើយើងត្រូវធ្វើដូចម្តេច ដើម្បីចិញ្ចឹមមាន់បានល្អប្រសើរ? ៣-បើសិនយើងមានថ្នាំចាក់ការពារមាន់តើយើងត្រូវចាក់វាយ៉ាងដូចម្តេចខ្លះ?	
១២៧	រៀនសរសេរ	-នើនកំពុងតែជិះលើឬស្សីដែលគេធ្វើឈ្នាន់ពីរសំរាប់ជាន់ ។ -មាន់របស់នើនកំពុងតែចឹកស្រូវក្នុងកាផាមួយ ។
១២៨	ចូរអោយសិស្សសរសេរតែងជាអត្ថបទមួយ ឬរឿងផ្សេងៗ នៅក្នុងតារាងខាងក្រោមនេះ ៖	
១២៩	**មេរៀនទី៩៧**	
	បង្រៀនជើងព្យញ្ជនៈ	□ ្យ
	ពាក្យគន្លឹះ	**អណ្តូត បាយ**
១៣០	រៀនអាន	
	<u>បងយ៉ាងជាមនុស្សឧស្សាហ៍និងចេះថែរក្សាខ្លួន</u> នៅពេលល្ងាចថ្ងៃចន្ទ បងយ៉ាងបាននិយាយប្រាប់អោយម្តាយដាំបាយពីព្រលឹម ពីព្រោះគាត់ត្រូវការខ្ចប់បាយ ដើម្បីទៅជំរះចំការប្រវាស់ដៃជាមួយ នឹងមិត្តភក្តិរបស់គាត់ ។ នៅពេលព្រឹកថ្ងៃចន្ទនោះ ម្តាយរបស់បងយ៉ាងក្រោកតាំងពីព្រលឹមមកដាំបាយអោយគាត់ ។ រហូតដល់ម៉ោងប្រាំមួយព្រឹក បាយសម្លរបស់ម្តាយគាត់ឆ្អិន ។ ធម្មតាបងយ៉ាងក្រោកនៅម៉ោងប្រាំមួយ តែព្រឹកនោះគាត់ដេករហូតដល់ម៉ោងប្រាំមួយកន្លះ ដោយសារតែគាត់មានផ្តាសាយក្នុងខ្លួនហើយដេកមិនសូវលក់ ។ នៅថ្ងៃនោះ បងយ៉ាងបានរកចាប់កណ្តូបនៅក្នុងចំការមិត្តភក្តិរបស់គាត់ ដើម្បីយកទៅអោយសត្វសារិកាកែវរបស់គាត់ស៊ី ។ នៅពេលដែលគាត់កំពុងតែស្វែងរកកណ្តូប ស្រាប់តែជើងរបស់គាត់មុតនឹងស្មៅតូចៗ ហើយចេញឈាម ។ វិលត្រឡប់មកផ្ទះវិញ នៅពេលល្ងាចគាត់ទៅជួបលោកគ្រូពេទ្យ ដើម្បីសុំថ្នាំព្យាបាលជើងនិងថ្នាំព្យាបាលផ្តាសាយផងដែរ ។ សំរាប់អាហារពេលល្ងាច ម្តាយរបស់គាត់បានស្លស្លៃស្លឹកពាបនិងត្រីក្រៀម ។ បន្ទាប់មក បងយ៉ាងហូបបាយពេលល្ងាចជាមួយនឹងឪពុកម្តាយបងប្អូនរបស់គាត់ ។ បងយ៉ាងហូបបាយអស់ពីរចានសម្លពីរចាន ។ ក្រោយពីហូបបាយពេលល្ងាចហើយ គាត់ទៅលេងមិត្តភក្តិរបស់គាត់ ដើម្បីប្រាជ្ញលេងជាមួយគ្នា ព្រមទាំងច្របាច់ខ្នង ច្របាច់ខ្លួនប្រាណអោយគ្នាទៀតផង ។ យប់ម៉ោងដប់ បងយ៉ាងនិងមិត្តភក្តិរបស់គាត់នាំគ្នាគេង នៅលើគ្រែជាមួយគ្នា ៕	
១៣១	រៀនសរសេរ	-កាកកំពុងរែងអង្ករក្នុងផ្ទះ ។ -បងកាកកំពុងដាំបាយនៅក្នុងផ្ទះបាយ ។
១៣២	ចូរជ្រើសរើសជើងព្យញ្ជនៈ " ្យ " សរសេរប្រកបអោយបានបីពាក្យខាងក្រោមនេះ ៖	

១៣២	ជ្រើសរើសបីពាក្យដែលបានសរសេរខាងលើ ហើយតែងអោយបានបីប្រយោគខាងក្រោមនេះ ៖
១៣៣	រៀនអាន
	<u>រឿងមនុស្សម្នាក់ចិញ្ចឹមគោនិងក្របីនៅភូមិជ្រកព្រីម</u> មានមនុស្សម្នាក់ធ្វើជាពេទ្យសត្វនៅក្នុងភូមិជ្រកព្រីម ។ ថ្ងៃមួយមានមនុស្សម្នាក់ក្នុងភូមិទៅជួបពេទ្យសត្វនោះ ដោយសារតែសត្វចិញ្ចឹមរបស់គាត់មានជំងឺ ។ ពេទ្យសត្វរូបនោះក៏សួរទៅមនុស្សម្នាក់នោះ ៖ "តើអ្នកមករកខ្ញុំមានការអីដែរ?" ម្ចាស់សត្វឈឺនោះឆ្លើយ ៖ "បាទ! លោកគ្រូ ខ្ញុំមកនេះគឺចង់អោយលោកគ្រូជួយមើលក្របីរបស់ខ្ញុំឈឺ" ។ ពេទ្យសត្វនោះក៏សួរទៀត ៖ "តើក្របីនោះឈឺយ៉ាងដូចម្ដេចទៅ សូមរៀបរាប់អោយខ្ញុំស្ដាប់សិនមើល?" ម្ចាស់ក្របីរៀបរាប់ ៖ "វាមិនស៊ីស្មៅហៀទឹកមាត់និងសំបោរ ។ សត្វខ្លះទៀតវាឈឺរហូតដល់ងាប់ក៏មានដែរ" ។ ពេទ្យសត្វសួរទៀត ៖ "និយាយអីចឹង តើសត្វដែលងាប់ហើយនោះ ចេញរោគសញ្ញាអ្វីខ្លះ?" ម្ចាស់ក្របីនិយាយប្រាប់ ៖ "ក្របីដែលងាប់ ឈឺដូចក្របីផ្សេងៗទៀតដែរ តែវាឈឺខុសគ្នាបន្តិចបន្តួច ។ ក្របីដែលឈឺងាប់ ដំបូងវាហើមកពិបាកដកដង្ហើម ពោះប៉ោងធំ ក្រោយមកវាងាប់ទៅ ។ ពេទ្យសត្វសួរទៀត ៖ "តើពួកឯងបានពន្លះសាច់ក្របីដែលងាប់ទៅហើយនោះដែរឬទេ?" ម្ចាស់ក្របីនិយាយ ៖ "បាទ! លោកគ្រូពេទ្យពួកខ្ញុំបានពន្លះសាច់វាដែរ តែមិនបានស៊ីសាច់វាទេ ។ នៅពេលដែលពួកខ្ញុំពន្លះសាច់វា ស្រាប់តែឃើញសាច់ខាងក្នុងស្អួតទាំងអស់ ថ្លើមវាមានស្នាមជាំគ្រប់កន្លែងផងដែរ" ។ ពេទ្យសត្វភូមិនោះគិតមួយស្របក់អំពីជំងឺនោះ ។ គាត់ដឹងអំពីជំងឺនោះ គឺជំងឺសាទឹកព្រោះជំងឺនេះ ចេញរោគសញ្ញាបែបនេះ ។ ក្រោយមកគាត់ក៏យកថ្នាំមកព្យាបាលក្របីនោះភ្លាម ។ នៅពេលពេទ្យសត្វភូមិនោះធ្វើដំណើរតាមផ្លូវ គាត់បានឃើញក្របីជាច្រើនកើតជំងឺព្រោះអីខែនោះជាខែភ្លៀងដើមឆ្នាំ ដែលធ្វើអោយគោក្របីកើតជំងឺសាទឹក ។ ពេទ្យសត្វភូមិរូបនោះធ្វើដំណើរជាមួយម្ចាស់ក្របីបណ្ដើរ និងជជែកគ្នាអំពីថ្នាំការពារសត្វទាំងនោះបណ្ដើរ ។ ពេទ្យនោះនិយាយ ៖ "នៅខែ១២នេះ មានសត្វក្របីជាច្រើនកើតជំងឺសាទឹក មិនខុសគ្នាពីក្របីរបស់បងឯងដែលបាននិយាយប្រាប់ខ្ញុំនោះឡើយ ។ ជំងឺសាទឹក នៅពេលវាឈឺបន្តិចបន្តួចយើងអាចព្យាបាលវាជា តែបើវាឈឺធ្ងន់ធ្ងរហើយ យើងមិនអាចព្យាបាលវាបានឡើយ" ។ ម្ចាស់ក្របីក៏សួរទៅកាន់ពេទ្យនោះទៀត តើយើងគួរតែរកវិធីអ្វីខ្លះ ដើម្បីការពារកុំអោយកើតជំងឺនោះបាន ។ ពេទ្យសត្វ ៖ "បើយើងមិនចង់អោយក្របីរបស់យើងកើតជំងឺនោះមានតែចាក់ថ្នាំការពារប៉ុណ្ណោះ ។ យើងអាចចាក់នៅពេលវាមិនទាន់កើតជំងឺ ផ្ទុយទៅវិញបើក្របីកើតជំងឺរួចទៅហើយ យើងមិនអាចចាក់ថ្នាំការពារបានទេ ។ យើងអាចចាក់ថ្នាំព្យាបាលអោយវាបាន តែមិនអាចព្យាបាលអោយជាទាំងអស់ទេ ។ បើយើងបានចាក់ថ្នាំការពារជាមុននោះប្រសើរជាងការព្យាបាល ។ ថ្នាំការពារជំងឺសាទឹកអាចការពារក្របីរយៈពេលប្រាំមួយខែ ។ ដូច្នេះយើងត្រូវចាក់ថ្នាំការពារអោយវាមួយអាទិត្យម្ដង" ។ ពេទ្យសត្វនិយាយទៀតថា ថ្ងៃក្រោយ បើសិនបានឃើញគោក្របីងាប់ដោយសារជំងឺ សូមកុំស៊ីសាច់វាអោយសោះ ព្រោះវា

	អាចធ្វើអោយយើងឈឺ ។ មកដល់កន្លែងក្របីឈឺ ពេទ្យសត្វនិយាយ ៖ "ជំងឺក្របីរបស់បងឯងនេះ គឺជាជំងឺសាទឹក ។ ឥឡូវយើងត្រូវចាក់ថ្នាំ «អ៊ុកស៊ី» សំរាប់ព្យាបាលវា ។ ឯក្របីរបស់បងដែលមិនទាន់ឈឺ យើងក៏ត្រូវចាក់ថ្នាំការពារអោយវាដែរ" ។ បន្ទាប់មកពេទ្យសត្វព្យាបាលក្របីនោះ រយៈពេលបីថ្ងៃហើយបានជាសះស្បើយពីជំងឺ ។ ប្រជាជនជិតខាងរបស់គាត់បានឃើញក្របីនោះ ជាសះស្បើយពីជំងឺមែន ។ ប្រជាជនក្នុងភូមិនោះទាំងមូល បានអោយពេទ្យសត្វភូមិរូបនោះ ចាក់ថ្នាំការពារគោក្របីរបស់ពួកគេទាំងអស់ ។ ពេទ្យសត្វភូមិក៏ចាក់ថ្នាំការពារអោយគោក្របីក្នុងភូមិនោះ តាមការស្នើសុំរបស់ពួកគេ ។ ក្រោយមកគោក្របីក្នុងភូមិនោះ លែងមានជំងឺដូចកាលពីថ្ងៃមុនទៀតហើយ ៕ **<u>សំនួរ</u>** -នៅពេលគោក្របីរបស់យើងឈឺ តើយើងត្រូវធ្វើដូចម្តេច? -នៅពេលពេទ្យសត្វធ្វើដំណើរតាមផ្លូវ តើគាត់បានជួបប្រទះអ្វីខ្លះ?	
១៣៦	ចូរអោយសិស្សសរសេរតែងជាអត្ថបទមួយ ឬក៏រឿងផ្សេងៗនៅក្នុងតារាងខាងក្រោមនេះ ៖	
១៣៧	**មេរៀនទី៥៨**	
	បង្រៀនព្យញ្ជនៈនិងជើងព្យញ្ជនៈ	ហ្វ
	ពាក្យគន្លឹះ	**រុយ ទាញខ្សែ**
១៣៨	រៀនអាន	
	<u>រៀនអានប្រយោគដែលមានជើង(្វ)</u> -ពូរបស់ខ្ញុំទៅដួសជ័រទឹកក្នុងព្រៃ ។ គាត់បានឃើញសត្វទោចនិងកូនរបស់វានៅលើមែកឈើ ។ -កូនទោចនោះប្រលែងលេងជាមួយមេរបស់វា ។ វាលោតចុះឡើងនៅលើមែកឈើនោះ ។ -ឪពុករបស់ខ្ញុំបាននិយាយប្រាប់ ៖ "សត្វទោចមិនចេះស៊ីស្រូវស៊ីពោតដូចសត្វស្វាទេ វាចេះស៊ីផ្លែឈើតែប៉ុណ្ណោះ ។ -នៅពេលខ្ញុំពេញវ័យ ជីតារបស់ខ្ញុំបញ្ជាខ្ញុំអោយទៅតាមគេកាប់ខ្សែផ្តៅអូសពីព្រៃមកផ្ទះ ដើម្បីយកមកធ្វើខ្សែកាផា សៀវ ឬក៏ចងមុខចង្អេរ ឈ្នាងជាដើម ។ -ខ្ញុំកាប់ផ្តៅបានច្រើនលើសគេដប់ខ្សែ ។ គេកាប់ទាញផ្តៅតិចជាងខ្ញុំដប់ខ្សែ ។	
១៣៩	រៀនសរសេរ	-នើនទៅកាប់ខ្សែហើយអូសនិងបិតវាផង ។ -នើនកំពុងតែពន្លះសាច់ជ្រូកដើម្បីយកទៅលក់ ។
១៤០	ចូរជ្រើសរើសព្យញ្ជនៈ " ហ " និងជើង " ្វ" សរសេរប្រកបអោយបានបីពាក្យ ៖	

	ជ្រើសរើសបីពាក្យដែលបានសរសេរ ហើយតែងអោយបានបីប្រយោគខាងក្រោមនេះ ៖
១៤១	រៀនអាន
	<u>រឿងបេះផ្លែពពាយ</u> កាលពីព្រេងនាយមានស្រីក្រមុំពីរនាក់ ជាមិត្តសំឡាញ់និងគ្នា ម្នាក់ជាអាប ម្នាកទៀតជាមនុស្ស ។ ស្រីក្រមុំដែលចេះអាបបានបបួលសំលាញ់ដែលជាមនុស្សធម្មតានោះ ៖ "នែ៎សំឡាញ់! តោះយើងទៅបេះផ្លែពពាយ" ។ នាងជាមនុស្សធម្មតាតប ៖ "ចាំ! តោះយើងទៅ" ។ និយាយហើយ ក្រមុំទាំងពីរនាំគ្នាទៅដល់កន្លែងដើមពពាយ ។ ក្រមុំជាអាបប្រាប់ទៅសំឡាញ់ដែលជាមនុស្សធម្មតា ៖ "សំឡាញ់ឯងឡើងបេះទៅ" ។ ក្រមុំជាមនុស្សធម្មតាឡើងទៅបេះផ្លែពពាយទម្លាក់ចុះមកក្រោម ។ ចំណែកសត្វខ្លាតែងតែមកស៊ីពពាយរាល់ព្រឹក ។ ពេលក្រមុំជាមនុស្សធម្មតាចង់ចុះពីដើមឈើមកក្រោមដែរ តែចុះមិនបានសោះ ព្រោះសំឡាញ់ជាអាបបានធ្វើអោយនាងចុះមកក្រោមមិនបាន ។ ក្រមុំជាអាបនៅខាងក្រោមដឹងថាខ្លាតែងតែមកស៊ីផ្លែពពាយរាល់ព្រឹកក៏រត់ទៅផ្ទះវិញ ។ ឯក្រមុំជាមនុស្សធម្មតាក៏ជាប់នៅលើដើមពពាយនោះទៅ ដោយខ្លួនចុះមកក្រោមមិនរួច ។ មួយសន្ទុះក្រោយមក ស្រាប់តែមានខ្លាមួយក្បាលមកដល់ដើមពពាយព្រមទាំងគ្រហឹមទៀតផង ។ ខាងឆ្វេងធុំក្លិនស្នៅខាងស្តាំធុំក្លិនចេក ខ្លានោះងើយមើលទៅលើដើមពពាយ ក៏ប្រទះឃើញក្រមុំម្នាក់ ។ ខ្លាសួរ ៖ "អ្នកណាគេនៅលើដើមពពាយនេះ?" នាងតប ៖ "អ៊ូ! ខ្ញុំទេលោកតា" ។ នាងនិយាយដូច្នេះព្រោះតែនាងមិនហ៊ានហៅឈ្មោះខ្លានោះ ។ ខ្លាសួរទៀត ៖ "នាងមកទីនេះធ្វើអី?" ក្រមុំនោះប្រាប់ ៖ "លោកតាអើយ! ខ្ញុំមិនដឹងទេនាងអាបនោះនាំខ្ញុំមក ហើយកុហកខ្ញុំថាមកបេះផ្លែពពាយ" ។ ខ្លានោះនឹកអាណិតនាង ហើយពោល ៖ "អ៊ូ! តាអាណិតចៅឯងណាស់ ចុះមកចៅ" ។ ក្រមុំនោះនិយាយទៀត ៖ "បើចង់ខាំៗនៅទីនេះចុះ បើចង់ស៊ីៗនៅទីនេះចុះ" ។ ខ្លានិយាយ ៖ "អ៊ូ! សំដីរបស់ចៅចំលែកមែនទែន ចុះមកចៅ" ។ ខ្លាដាក់ជណ្តើរអោយនាងចុះពីលើដើមពពាយ ។ ពេលនាងចុះមកដល់ក្រោមហើយខ្លានោះនិយាយ ៖ ""ចៅអើយ! ជិះលើយើងមក" ។ នាងក្រមុំក៏ជិះលើខ្នងខ្លានោះទៅ ។ នៅពេលចេញដំណើរ នាងក្រមុំនិយាយ ៖ "សូមនាំខ្ញុំទៅតាមផ្លូវដែលមានព្រៃចាស់ ដែលមានបន្លា" ។ ខ្លាលាន់មាត់ ៖ "យ៉េ! សំដីចៅចំលែកណាស់" ។ និយាយហើយ ខ្លានាំនាងទៅតាមផ្លូវល្អ រហូតទៅដល់ទឹកអូរ ។ ខ្លានិយាយ ៖"ចៅចុះទៅយើងចុះឆ្លងអូរហើយ" ។ នាងចុះពីលើខ្នងខ្លាហើយពោល ៖ "បើចង់ខាំៗនៅទីនេះចុះបើចង់ស៊ីៗនៅទីនេះចុះ" ។ ខ្លានិយាយ ៖ "សំដីចៅពិតជាចំលែកណាស់" ។ បន្ទាប់មកនាងជិះពីលើខ្នងខ្លានោះទៀត ។ ខ្លាធ្វើដំណើរបន្តហើយគ្រហឹមទៀតផង ។ ពេលទៅដល់ផ្ទះហើយខ្លានិយាយ ៖ "ចៅឯងនៅទីនេះហើយណាំជួយថែរក្សាកូនរបស់យើងផង" ។ នាងតប ៖ "ចាំ! លោកតា" ។ បន្ទាប់មកខ្លានោះបានប្រាប់ទៅប្រពន្ធ ៖ "ឯងអើយ! យើងមានចៅម្នាក់ហើយ ទុក

នាងនៅទីនេះសំរាប់មើលថែរក្សាកូនរបស់យើង ។ យើងយកពេលនេះដើម្បីទៅរកត្រី" ។ ប្រពន្ធឆ្លើយ ៖ "ចាំ!" ។ ខ្លាប្រាប់នាងនោះ ៖ "ថ្ងៃស្អែក ចៅឯងថែរក្សាកូនយើងផងណា ហើយដាំទឹកក្តៅអោយពុះមែនទែន រួចចាក់លើកូនរបស់យើងអោយវាស្លាប់អស់ទៅ" ។ នាងតប ៖ "ចាំ!លោកតា" ។ ខ្លាពីរនាក់ប្តីប្រពន្ធនោះតែងតែនិយាយពាក្យផ្ទុយ ។ ចំណែកនាងក្រមុំនោះដឹងថាខ្លានិយាយតែពាក្យផ្ទុយដូច្នេះ ក៏ដាំទឹកក្តៅឧណ្ហៗ ហើយនាំកូនខ្លាទៅងូតទឹកនៅកន្លែងដីខ្សាច់តាមធម្មតា ។ ងូតទឹករួចហើយ នាងនាំកូនខ្លាត្រឡប់ទៅផ្ទះវិញ ។ នៅពេលល្ងាចខ្លាទាំងពីរត្រឡប់មកពីរកត្រីវិញ ហើយនិយាយ ៖ "សាច់ប្រើសសាច់ឈ្លូសរបស់យើងនេះទុកអោយចៅស្រីឯង ចំណែកសាច់មនុស្សនេះទុកសំរាប់អោយយើងស៊ី ។ ចៅហូបសាច់ប្រើសសាច់ឈ្លូសនេះទៅ" ។ ខ្លាក្អែរចេញសាច់ទាំងនោះមក ។ វាយកទៅលាងអោយស្អាត ចំណែកសាច់ប្រើសសាច់ឈ្លូសទុកអោយចៅស្រីនោះហូប ។ ពេលដេកយប់ខ្លានោះប្រាប់ទៅកូន ៖"កូនឯងចូលដេកខាងនោះទៅ ទុកអោយបងស្រីឯងគេដេកនៅឯនេះ" ។ កូនខ្លាតប ៖ "បាទ" ។ ពេលយប់ជ្រៅកូនខ្លាចង់មកស៊ីនាងនោះ ចំណែកនាងចេះតែបង្រះ ។ ខ្លាជាឳពុកឮចៅស្រីបង្រះដូច្នេះសួរចៅស្រីនោះ ៖ "ចៅស្រីបង្រះធ្វើអ្វី?" ។ នាងប្រាប់ ៖ "ចាំ! លោកតា មូសខាំខ្ញុំ" ។ ខ្លានោះដឹងថាកូនរបស់ខ្លួនលេងសើចជាមួយចៅស្រីនោះ ក៏ប្រាប់ទៅកូន ៖ "កូនឯងកុំលេងអីចឹងអី នាំគ្នាដេកទៅ" ។ កូនខ្លាទាំងអស់ស្តាប់ឳពុកក៏នាំគ្នាដេក ។

លុះស្អែកឡើងចៅស្រីនោះធ្វើការងារដូចធម្មតា ។ ពេលដែលខ្លាមកពីព្រៃវិញ ឃើញចានឆ្នាំងស្អាតបាទទាំងអស់ ហើយទុកដាក់បានល្អទៀត ក៏ពិភាក្សាជាមួយប្រពន្ធ ៖ "ចៅស្រីនេះនាងពិតជាមនុស្សត្រឹមត្រូវមែន" ។ នៅវេលាខ្លានិងប្រពន្ធពិភាក្សាគ្នា ចៅស្រីធ្វើជាឈឺពោះ និងធ្វើជាគ្រុនទៀតផង ហើយប្រាប់ទៅខ្លា ៖ "លោកតាខ្ញុំគ្រុននិងឈឺធ្ងន់ណាស់ សូមលោកតាជូនខ្ញុំត្រឡប់ទៅវិញទៅ" ។ ខ្លាតប ៖ "បើអីចឹងថ្ងៃក្រោយចៅឯងមកលេងតាទៀតណាំ" ។ នាងតប ៖ "ចាំ! លោកតា" ។

ខ្លាជូននាងទៅវិញ ។ ពេលទៅជិតដល់ ឃើញភូមិលឹមៗ ខ្លាខាំសត្វទន្សោងមួយអោយចៅស្រី រួចនាងយកសាច់សត្វទន្សោងទៅផ្ទះ ។ ពេលទៅដល់ផ្ទះ ក្រមុំជាអាបសួរ ៖"នែ៎ សំឡាញ់! តើឯងបានសាច់សត្វទន្សោងនេះដោយរបៀបណាដែរ?" ។ នាងជាមនុស្សនិយាយ ៖ "ឯងនេះខូចណាស់កុហក ទុកចោលយើងម្នាក់ឯងនៅលើដើមឈើ សំណាងដែលខ្លាវាទុកអោយខ្ញុំមានជីវិត" ។ ក្រមុំអាបនិយាយទៀត ៖ "បើអីចឹងយើងទៅបេះផ្លែពពាយនោះម្តងទៀតណាំសំឡាញ់ ហើយខ្ញុំជាអ្នកឡើងបេះម្តង" ។ សម្លាញ់ជាមនុស្សយល់ព្រមទៅម្តងទៀត ។

ពេលទៅដល់ដើមពពាយ ក្រមុំចេះអាបឡើងបេះផ្លែពពាយ ហើយចុះមកវិញមិនបានទេ ព្រោះជាប់នៅលើចុងឈើ ។ មួយសន្ទុះក្រោយមកខ្លាមកដល់ ។ វាគ្រហឹមពីចំងាយ ៖ "ខាងឆ្វេងធុំក្លិនស្មៅ ខាងស្តាំធុំក្លិនចេក" ។ ក្រមុំចេះអាបនោះធ្វើជានិយាយដូចក្រមុំមុន ៖ "ខ្ញុំទេលោកតា" ។ ខ្លាពោល ៖ "ចុះមកចៅ" ។ ក្រមុំចេះអាបនិយាយ ៖ "លោកតាកុំខាំខ្ញុំអី

<table>
<tr><td></td><td colspan="2">ណាំ” “យី! ចៅស្រីនេះសំដីវាត្រង់ មែន” ។ ក្រមុំចេះអាបសួរទៅខ្លា ៖ “ទៅតាមផ្លូវណាលោកតា?” ខ្លាប្រាប់ ៖ “ស្រេចតែចិត្តចៅទេ” ។ ក្រមុំចេះអាបនោះនិយាយ ៖ “បើអីចឹងលោកតាកុំនាំខ្ញុំទៅតាមផ្លូវបន្លា និងផ្លូវដែលមានច្រាំងអោយសោះណាំ” ។
ខ្លានោះមិនចូលចិត្តនិយាយដោយត្រង់ៗទេ ។ ខ្លានាំក្រមុំចេះអាបនោះទៅតាមផ្លូវដែលមានបន្លា ហើយក្រមុំអាបមុតបន្លាឈាមពេញខ្លួនប្រាណទាំងអស់ ។ ពេលទៅដល់ផ្ទះខ្លាប្រាប់ទៅប្រពន្ធ ៖ “នែ៎! ម៉ែវា យើងបានចៅមួយទៀតហើយណា ចៅនេះសំដីវាត្រង់ណាស់” ។ ខ្លានោះបង្គាប់ដូចក្រមុំពីមុននោះដែរ ៖ “ចៅតើថ្ងៃនេះងូតទឹកអោយកូនយើងយ៉ាងម៉េចដែរ?” “អូ! ខ្ញុំភ្លេចងូតអោយវាទៅហើយតា” ។ តាខ្លានិយាយ ៖ “អ៊ំ! សំដីរបស់ចៅនិយាយត្រង់មែន” ។ ពេលយប់កូនខ្លាលូកទៅកេះក្រមុំចេះអាបនោះ ហើយនាងបង្រះ ។ ខ្លាជាឪពុកឮនាងបង្រះដូច្នេះសួរ ៖ “ហេតុអីចៅឯង ចេះតែបង្រះយ៉ាងនេះ?” ។ នាងប្រាប់ ៖ “កូនតាឯងយកដៃមកកេះខ្ញុំ” ។ “យី! ពាក្យសំដីចៅឯងត្រង់ៗណាស់” ។
លុះស្អែកឡើងក្រមុំចេះអាបនោះប្រាប់កូនខ្លា ៖ “នែ៎! ប្អូនៗទាំងអស់អើយ! ពុកម៉ែប្អូនបានប្រាប់ថា អោយប្អូនៗទាំងអស់ដេកអោយត្រង់នៅលើដីខ្សាច់នេះ ដើម្បីងាយស្រួលងូតទឹក” ។ បន្ទាប់មកក្រមុំចេះអាប យកទឹកក្តៅជះលើកូនខ្លាទាំងនោះងាប់អស់ទៅ ពេលនោះក្រមុំចេះអាបនិយាយ ៖ “ហេតុអីខ្លាមិនអោយរបស់មកយើងបន្តិចសោះ ឯនាងក្រមុំពីមុនម្តេចខ្លានោះចេះអោយសាច់ទន្សោងទៅវា” ។ ចំណែកខ្លានិងប្រពន្ធត្រឡប់ពីព្រៃមកវិញ ថែមទាំងគ្រហឹមពីចំងាយទៀត ។ មើលផ្ទះរបស់ខ្លួនឃើញភ្លើងឆេះអស់ ហៅកូនៗ មិនឮឆ្លើយតប ខ្លាក៏ស្រែកហៅនាងចេះអាប ៖ “ចៅអើយ! កូនយើងនៅឯណា?” ក្រមុំចេះអាបប្រាប់ ៖ “ខ្ញុំមិនដឹងទេលោកតា អម្បាញ់មិញខ្ញុំឃើញវាលេងនៅឯវាលខ្សាច់ឯណោះ” ។ ខ្លាឮដូចនេះទៅមើលកូននៅកន្លែងដីខ្សាច់ ស្រាប់តែឃើញកូនងាប់អស់ ។ ខ្លាខឹងណាស់ ក៏ខាំបោកក្រមុំចេះអាបនោះស្លាប់ទៅ ៕
<u>សំនួរ</u>
១-តើក្រមុំពីរនាក់នោះ ជាមនុស្សចេះអាបទាំងពីរនាក់ឬក៏យ៉ាងណា?
២-ក្រមុំមានអាបនិងក្រមុំអត់មានអាប តើមួយណាជាមនុស្សល្អនឹងសត្វខ្លា?</td></tr>
<tr><td>១៤៧</td><td colspan="2">មេរៀនទី៥៩</td></tr>
<tr><td></td><td>បង្រៀនស្រះ</td><td>ែ □ៀ</td></tr>
<tr><td></td><td>ពាក្យគន្លឹះ</td><td>បងតា</td></tr>
<tr><td>១៤៨</td><td colspan="2">រៀនអាន</td></tr>
<tr><td></td><td colspan="2"><u>បងតារៀនដាំសណ្តែក</u>
បងតារៀបការបានបីឆ្នាំមកហើយ ។ គាត់បានកូនពីរនាក់ គឺកូនប្រុសមួយនិងកូនស្រីមួយ ។ ប្តីរបស់គាត់ជាប្រជាជនអ្នកកសិករធ្វើចំការ ហើយគាត់ក៏ជាអ្នកចំការដែរ ។</td></tr>
</table>

	បងគារស់នៅជាមួយប្ដីគាត់រយៈពេលបីឆ្នាំកន្លងទៅ ។ ប្ដីគាត់នាំគាត់ធ្វើតែចំការមួយមុខប៉ុណ្ណោះ ។ ពួកគេខិតខំធ្វើចំការសំរាប់ដាំស្រូវរាល់ឆ្នាំ ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ជាពិសេសគឺកូនរបស់ពួកគេពីរនាក់ ។ តែគ្រួសាររបស់គាត់នៅតែខ្វះម្ហូបអាហារនិងខោអាវស្លៀកពាក់ដដែល ។ បងប្អូនជិតខាងបាននាំគ្នាដាំសណ្ដែក ដាំដើមឈើមានផ្លែ តែប្ដីរបស់គាត់មិនចង់ធ្វើតាមពួកគេទាំងនោះទេ ។ បងគាទើបនិយាយទៅប្ដីរបស់គាត់នោះ ៖ "នែ៎! ប៉ាវ៉ា តើគ្រួសាររបស់យើងនេះ ធ្វើដូចម្ដេចទៅអោយមានម្ហូបអាហារគ្រប់គ្រាន់ដូចគេ? ស៊ីអត់ស៊ីឃ្លានរាល់ឆ្នាំ បើដូចនេះឆ្នាំក្រោយ យើងសាកល្បងដាំសណ្ដែកសៀងសណ្ដែកដី ដូចគេមើល!" "បាទ! បើអីចឹងសាកល្បងទៅ" ។ ចូលដល់ឆ្នាំថ្មីបងគា និងប្ដីរបស់គាត់នាំគ្នាខំប្រឹងជំរះស្មៅនៅក្នុងចំការ រួចដាំសណ្ដែកដីសណ្ដែកសៀងលូតលាស់បានល្អណាស់ ។ ក្រោយមកពួកគេលក់សណ្ដែកទាំងនោះ អោយឈ្មួញក្នុងទីផ្សារ ហើយបានលុយយ៉ាងច្រើន ។ ពួកគេទិញសំភារៈប្រើប្រាស់ក្នុងគ្រួសារ ដូចជាខោអាវ អង្ករ អំបិល ប៊ីចេងបានគ្រប់គ្រាន់ ៕	
១៤៩	រៀនសរសេរ	-បងគាកំពុងតែស្វែងរកប្អូនរបស់គាត់ឈ្មោះបៀន -ប្អូនរបស់គាត់ឈ្មោះបៀនកំពុងតែហូបសណ្ដែកសៀង ។
១៥០	ចូរជ្រើសរើសស្រៈ " េ □ ្យ " ហើយសរសេរប្រកបអោយបានបីពាក្យខាងក្រោមនេះ ៖	
១៥០	ជ្រើសរើសបីពាក្យដែលបានសេរសេរខាងលើ ហើយតែងអោយបានបីប្រយោគខាងក្រោមនេះ ៖	
១៥១	រៀនអាន	
	<u>ជ្រូកមានជំងឺប៉ារ៉ាស៊ីត</u> គ្រួសារមួយបានចិញ្ចឹមជ្រូកដោយផ្ដល់ចំណីអោយវាដូចជា ៖ ដើមចេក ឬម្ហូបអាហារសេសសល់ពីមនុស្ស មានផ្លែត្រសក់ ផ្លែល្ពៅ ត្រាវ កន្ទក់ ឬក៏អោយជ្រូកនោះដើររកស៊ីចំណីដោយខ្លួនឯងក្នុងព្រៃ ដូចជា ដំឡូង និងជន្លេនជាដើម ។ ការបណ្ដោយអោយជ្រូកស៊ីចំណីបែបនេះ មិនងាយធំធាត់ល្អទេ ។ ប៉ារ៉ាស៊ីតគឺជាមេរោគតូចល្អិតម្យ៉ាង វាឆ្លងពីជ្រូកមួយទៅជ្រូកមួយទៀត គឺវាឆ្លងតាមចំណីដែលជ្រូកស៊ីជាមួយគ្នានោះ ។ ក្រោយពេលជ្រូកស៊ីចំណីហើយមេរោគប៉ារ៉ាស៊ីតតែងតែលួចស៊ីជាតិចំណី នៅក្នុងខ្លួនរបស់វា ឬក៏ជញ្ជក់ឈាម ដែលនាំអោយជ្រូកមិនងាយធំធាត់ល្អ ។ ចំណែកប៉ារ៉ាស៊ីតវិញកាន់តែធំ ហើយកាន់តែច្រើនឡើងៗថែមទៀត ។ ជ្រូកខំប្រឹងស៊ីចំណីរាល់ថ្ងៃ ប៉ុន្ដែខ្លួនរបស់វាមិនចេះធំធាត់ និងលូតលាស់ទេ ។ ប៉ារ៉ាស៊ីតតែងតែនៅក្នុងខ្លួន និងនៅលើស្បែករបស់ជ្រូក ។ ប៉ារ៉ាស៊ីតដែលនៅលើស្បែករបស់វាស្រដៀងនឹងដង្កែនិងចៃ ។ ប៉ារ៉ាស៊ីតទាំងនោះជ្រាបចូលក្នុងខ្លួនរបស់វាហើយ ក្លាយទៅជាព្រូនសំប៉ែត ឬក៏ព្រូនផ្សេងៗទៀត ។ យើងកុំភ្លេចថា មនុស្សក៏អាចកើតប៉ារ៉ាស៊ីតដែរ ដូចជាក្មេងតូចៗមានចៃនៅលើក្បាល និងព្រូនផ្សេងៗកើតដងខ្លួនរបស់វា ។ មានប៉ារ៉ាស៊ីតខ្លះកើតចេញពីជ្រូក ហើយឆ្លងរាលដាល	

	ទៅមនុស្ស ដូចជាព្រូនសំប៉ែតជាដើម ។ បើយើងហូបសាច់ជ្រូកដែលមានចុងអង្ករ ចំអិនមិនឆ្អិនល្អ នាំអោយយើងកើតមានព្រូនសំប៉ែតនៅក្នុងខ្លួន ។ បើយើងចង់ហូបសាច់ជ្រូកដែលមានចុងអង្ករ ត្រូវតែចំអិនវាអោយបានឆ្អិន ដើម្បីកុំអោយព្រូនសំប៉ែតនោះ កើតនៅក្នុងខ្លួនរបស់យើង ។ មនុស្សណាដែលកើតព្រូនសំប៉ែតនៅក្នុងខ្លួនហើយ ប្រាកដជាស្គម និង រាករូស អស់កំលាំង ។ ចំណែកជ្រូកវិញ បើកើតមានប៉ារ៉ាស៊ីតក្នុងខ្លួនហើយ វានឹងងាប់ ។ យើងអាចដឹងរោគសញ្ញាសំគាល់ប៉ារ៉ាស៊ីតបានដោយ ៖ - រមាស់ ក្រហមជុំវិញត្រចៀក - ស៊ីចំណីមិនចេះធំធាត់ - រោមបះ - ស្គម - រាករូស - ក្អកតិចៗ ។ បើឃើញរោគសញ្ញាសំគាល់ខាងលើនេះ មានតែថ្នាំអ៊ីវ៉ូមិចទើបអាចព្យាបាលជ្រូកដែលកើតប៉ារ៉ាស៊ីតបាន ។ ថ្នាំអ៊ីវ៉ូមិចគឺជាថ្នាំដែលល្អបំផុតសំរាប់សំលាប់ប៉ារ៉ាស៊ីតនៅក្នុងខ្លួននិងនៅលើស្បែករបស់ជ្រូក ។ បើប៉ារ៉ាស៊ីតងាប់អស់ពីក្នុងខ្លួន ជ្រូកក៏មានសុខភាពល្អនឹងឆាប់ធំធាត់ហើយ ស្បែករបស់វារលោងហើយលែងមានរមាស់ទៀតដែរ ។ មានអ្នកភូមិខ្លះហៅថ្នាំអ៊ីវ៉ូមិចថា «ថ្នាំធ្វើអោយជ្រូកឆាប់ធំ» តាមការពិតថ្នាំនោះមិនមែនធ្វើអោយជ្រូកឆាប់ធំទេ គ្រាន់តែវាអាចសំលាប់ប៉ារ៉ាស៊ីត កុំអោយវាលួចស៊ីជាតិចំណីនៅក្នុងខ្លួនជ្រូកតែប៉ុណ្ណោះ ។ សត្វជ្រូកភាគច្រើនកើតប៉ារ៉ាស៊ីត ។ មានមនុស្សមួយចំនួនបានសាកល្បងប្រើប្រាស់ថ្នាំអ៊ីវ៉ូមិចចាក់ទៅសត្វជ្រូក ទោះបីសត្វជ្រូកពួកគេគ្មានជំងឺក៏ដោយ ។ មេរោគប៉ារ៉ាស៊ីត តែងតែប៉ះពាល់ដល់សុខភាពសត្វពាហនៈ ដូចជាគោក្របី មាន់ទា ។ល ។ បើមានអ្នកណាមួយចង់ដឹងចង់យល់អំពីជំងឺប៉ារ៉ាស៊ីត ត្រូវតែទាក់ទងជាមួយនឹងបសុពេទ្យខេត្ត ឬក៏បសុពេទ្យភូមិក៏បាន ។ ទាំងពីរកន្លែងនេះអាចផ្ដល់ព័ត៌មានណែនាំនឹងការពារ ឬក៏ព្យាបាលសត្វ ។ ពួកគេមានថ្នាំអាចការពារនិងព្យាបាលជំងឺសត្វទាំងនោះតាមការដកពិសោធន៍នឹងបច្ចេកទេស ហើយពួកគេមានជំនាញបច្ចេកទេស ខាងចិញ្ចឹមសត្វគ្រប់ប្រភេទផងដែរ ៕ __សំនួរ__ -ពេលយើងចិញ្ចឹមសត្វជ្រូក តើត្រូវផ្ដល់ចំណីអ្វីខ្លះដល់វា? -ពាក្យថាប៉ារ៉ាស៊ីត មានន័យដូចម្ដេច? -បើយើងចង់យល់ដឹងអំពីមេរោគប៉ារ៉ាស៊ីត តើយើងគួរទាក់ទងជាមួយអ្នកណា?

១៥៥	**មេរៀនទី៦០**	**មេរៀនរំលឹកឡើងវិញ**
១៥៥	រៀនអាន	

<u>រឿងស្វា</u>

កាលពីព្រេងនាយ មានស្វាឈ្មោលមួយក្បាលរស់ នៅក្នុងព្រៃជ្រៅដ៏ស្ងាត់ជ្រងំតែម្នាក់ឯង ។ មានថ្ងៃមួយ ស្វានោះលោតលេងចុះឡើងៗ ពីមែកឈើមួយទៅមែកឈើមួយ លោតពីមុខទៅក្រោយ ពីក្រោយទៅមុខ ហើយក្រលេកចុះមកក្រោម ស្រាប់តែឃើញផ្លែឈើដែលគេដាក់ពីលើក្រដាសមួយសន្លឹក ។ ក្រោមក្រដាសមួយសន្លឹកនោះគេជីករណ្ដៅយ៉ាងជ្រៅ ។ ស្វានោះមិនបានដឹងទេថា ពីក្រោមក្រដាសនោះមានរណ្ដៅមួយដ៏ជ្រៅទេ ។ ស្វាឃើញផ្លែឈើនោះហើយក៏ ស្ទុះលោតចុះមកក្រោម ដើម្បីយកផ្លែនោះស៊ី ហើយក៏ធ្លាក់ទៅក្នុងរណ្ដៅនោះទៅ ។ ស្វាភ័យណាស់ព្រោះរកផ្លូវឡើងមកលើមិនបាន ។ អស់តិរិះស្វាក៏នៅស្ងៀម ។ មួយសន្ទុះក្រោយមកទន្សាយមួយបានមកដល់ ព្រមទាំងអើតមើលនៅក្នុងរណ្ដៅនោះ ឃើញស្វាមួយក្បាល ។ ស្វាឃើញទន្សាយហើយនិយាយ៖ "បងទន្សាយអើយ! បងឯងមិនទៅរករណ្ដៅសំរាប់ទុកអោយហើយទេ បន្តិចទៀតមេឃរលំហើយ បងទន្សាយឯងច្បាស់ជាស្លាប់មិនខាន" ។ ទន្សាយបានលឺស្វាប្រាប់ដូច្នេះភ័យណាស់ក៏តបទៅស្វា៖ "បងស្វាអើយ! ខ្ញុំគ្មានរណ្ដៅសំរាប់នៅទេ តែខ្ញុំសូមនៅជាមួយបងស្វាឯងផងបានដែរទេ?" ។ ស្វាឆ្លើយ៖ "ខ្ញុំអោយបងទន្សាយឯងនៅជាមួយនឹងខ្ញុំ តែខ្ញុំហាមមិនអោយកណ្ដាស់ "បាទ! មិនអីទេ" ។ និយាយហើយទន្សាយចុះទៅក្នុងរណ្ដៅជាមួយនិងស្វា ។

មួយសន្ទុះក្រោយមកខ្លាដើរកាត់ទីនោះ ។ ឃើញស្វានិងទន្សាយនៅក្នុងរណ្ដៅ ខ្លាក៏សួរ៖ "តើពួកបងឯងនៅក្នុងរណ្ដៅនេះធ្វើអ្វី?" ស្វានិងទន្សាយឆ្លើយ៖ "បងខ្លាឯងមិនទៅរករណ្ដៅសំរាប់នៅទេ បន្តិចទៀតមេឃនិងរលំហើយ បងខ្លាឯងប្រាកដជាស្លាប់មិនខាន" ។ ខ្លាឮស្វា និងទន្សាយនិយាយដូច្នេះភ័យណាស់ សួរទៅទន្សាយ និងស្វាទៀត៖ "បងស្វានិងបងទន្សាយអើយ! បើអីចឹងខ្ញុំសូមនៅជាមួយពួកបងឯងផងបានដែរទេ?" ទន្សាយនិងស្វាប្រាប់៖ "បាន ពួកខ្ញុំព្រមអោយបងឯងនៅជាមួយ តែពួកខ្ញុំសូមប្រាប់បងឯងអោយដឹងថាបងឯងកុំកណ្ដាស់អោយសោះណា៎" ។ ខ្លានិយាយ៖ "បាទ!" ។ និយាយហើយខ្លាចូលទៅក្នុងរណ្ដៅជាមួយទន្សាយ និងស្វានោះទៀតទៅ ។

មួយសន្ទុះក្រោយមករមាសដើរកាត់ទីនោះទៀត ស្រាប់តែឃើញស្វានិងទន្សាយព្រមទាំងខ្លាទៀតផង ។ ស្វា ទន្សាយ និង ខ្លា និយាយប្រាប់ទៅរមាសដូចមុនៗ ។ រមាសបានឮសត្វទាំងបីប្រាប់ដូច្នេះហើយ ភ័យណាស់ រមាសសុំចុះទៅក្នុងរណ្ដៅជាមួយសត្វទាំងបីនោះ ។ ពេលនោះស្វា ទន្សាយ ខ្លានិងរមាសនៅជាមួយគ្នា តែស្វា ទន្សាយ ខ្លា ហាមមិនអោយរមាសកណ្ដាស់ រមាសយល់ព្រម ហើយចុះទៅនៅជាមួយគ្នានៅក្នុងរណ្ដៅនោះទៅ ។ នៅពេលនោះ ស្វាចាប់ផ្ដើមរកមធ្យោបាយដើម្បីចេញពីរណ្ដៅ ។ នឹកឃើញមធ្យោបាយ ស្វាចាក់គទ

	ខ្លា ។ ស្វាចាក់ហើយចាក់ទៀត ។ ខ្លាអត់ទ្រាំមិនបានក៏ និយាយគំរាមទៅស្វា ៖ "ប្រយ័ត្នខ្ញុំលើកបងឯងបោះចេញពីរណ្ដៅនេះណា៎" ។ ស្វាបានឮខ្លាថាដូច្នេះ អរណាស់ តែមិនឃើញខ្លាលើកបោះសោះ ។ លុះយូរៗទៅស្វានឹកឃើញពាក្យរបស់ខ្លួន បាននិយាយពីមុនមកថា ហាមមិនអោយខ្លាកណ្ដាស់ ស្វាក៏យកមែកឈើតូចមួយមកត្បារច្រមុះខ្លា ដើម្បីអោយកណ្ដាស់ ។ ពេលខ្លាកណ្ដាស់ទន្សាយ ខ្លា និង រមាស ចាប់ស្វាបោះទៅលើមាត់រណ្ដៅ ។ ស្វាប្រលាក់ដីពេញខ្លួន ។ ទន្សាយ ខ្លានិង រមាស ចាញ់ប្រាជ្ញាស្វា ដោយបោះស្វានោះទៅលើ ។ ទន្សាយខ្លានិងរមាស់ នៅជាប់ក្នុងរណ្ដៅនោះរហូតទៅ ៕ **<u>សំនួរ</u>** -ហេតុអ្វីបានជាស្វាប្រើល្បិចដាក់ទន្សាយ? -តើស្វាអាចឡើងទៅខាងលើដែរឬទេ?
១៥៨	ចូរសរសេរអត្ថបទមួយ ទាក់ទងនឹងមេរៀន ការចិញ្ចឹមគោក្របី ឬ ជ្រូក មាន់នៅក្នុងតារាងខាងក្រោមនេះ ៖
១៥៩	ចំរៀងពួង ជួបជុំគ្នាសាមគ្គីភាព
១៦០	ព្យញ្ជនៈ និង ស្រៈ ភាសាពួង